# សៀវភៅ បិទ-បើក ស្តីពីសេវាតាមរកដៃគូ

សៀវភៅបិទបើកនេះ ជាជំនួយ
សម្រាប់ការផ្តល់ប្រឹក្សាក្នុងការតាមរក
ដៃគូ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើតេស្ត
រកមេរោគអេដស៍



# មាតិកា


| ល.រ | ប្រធានបទ | ទំព័រ |
|---|---|---|
| ១ | ប្រធានបទ | ២ |
| ២ | ការបង្ហាញរូបភាពសម្រាប់អ្នកផ្តល់ប្រឹក្សា | ៣ |
| ៣ | របៀបប្រើប្រាស់ឧបករណ៍ | ៤-៦ |
| ៤ | ការរៀបចំត្រៀមសម្រាប់ការប្រឹក្សា ដែលមានប្រសិទ្ធភាព | ៧ |
| ៥ | ជំនាញទំនាក់ទំនង និងផ្តល់ប្រឹក្សាលើកទឹកចិត្ត | ៨-៩ |
| ៦ | ប្រការគួរធ្វើ និងមិនគួរធ្វើរបស់អ្នកផ្តល់ប្រឹក្សា | ១០ |
| ៧ | ជំហានទី១៖ ប្រាប់ទៅអ្នកជំងឺអំពីសេវាតាមរកដៃគូដល់អ្នកជំងឺតម្រុយ | ១១-១២ |
| | ក. កិច្ចស្វាគមន៍ និងកិច្ចព្រមព្រៀងផ្ទាល់មាត់ | ១៣-១៤ |
| | ខ. សេវាតាមរកដៃគូ និងសារៈសំខាន់ | ១៥-១៦ |
| | គ. ការរក្សាការសម្ងាត់ | ១៥-១៦ |
| ៨ | ជំហានទី២៖ ស្រាវជ្រាវកត្តាប្រឈមរបស់អ្នកជំងឺ | ១៧-១៨ |
| ៩ | ជំហានទី៣៖ កត់ត្រាឈ្មោះដៃគូរួមភេទ និងអ្នកពាក់ព័ន្ធទាំងអស់ | ១៩-២០ |
| ១០ | ជំហានទី៤៖ ការស្រាវជ្រាវរកដៃគូបង្កអំពើហិង្សា | ២១-២២ |
| ១១ | ជំហានទី៥៖ ជម្រើសនៃការជូនដំណឹងដៃគូទៅអ្នកជំងឺ | ២៣-២៤ |

| ល.រ | ប្រធានបទ | ទំព័រ |
|---|---|---|
| ១២ | ជំហានទី៦៖ ធ្វើការជាមួយអ្នកជំងឺតម្រុយដើម្បីចាប់ផ្តើមទាក់ទងដៃគូ និងកូនរបស់គាត់ | ២៥-២៦ |
| | ជម្រើសទី១៖ ការបញ្ជូនដោយអ្នកជំងឺ | ២៥-២៦ |
| | ជម្រើសទី២៖ ការបញ្ជូនដោយអ្នកផ្តល់សេវា | ២៧-២៨ |
| | ជម្រើសទី៣៖ ការបញ្ជូនដោយមានកិច្ចព្រមព្រៀង | ២៩-៣០ |
| | ជម្រើសទី៤៖ ការបញ្ជូនដោយអ្នកជំងឺ និងអ្នកផ្តល់សេវា | ៣១-៣២ |
| ១៣ | បញ្ចប់វគ្គនៃការប្រឹក្សាលើសេវាតាមរកដៃគូ | ៣៣-៣៤ |
| ១៤ | ការវាស់វែងពីការតាំងចិត្ត និងភាពជឿជាក់ | ៣៥-៣៦ |
| ១៥ | ជួបជាមួយដៃគូផ្ទាល់ | ៣៧-៣៨ |
| ១៦ | ឧបសម្ព័ន្ធទី១៖ រំហូរនៃសកម្មភាពសំខាន់ៗរបស់ IPV | ៣៩ |
| ១៧ | ឧបសម្ព័ន្ធទី២៖ ទាក់ទងដៃគូតាមទូរស័ព្ទ | ៤០ |
| ១៨ | ឧបសម្ព័ន្ធទី៣៖ ទាក់ទងដៃគូដោយជួបផ្ទាល់ | ៤១ |
| ១៩ | ឧបសម្ព័ន្ធទី៤៖ ការធ្វើតេស្តរកមេរោគអេដស៍ | ៤២ |
| ២០ | សេចក្តីថ្លែងអំណរគុណ | ៤៣ |

# ប្រធានបទ និងការបង្ហាញរូបភាពសម្រាប់អ្នកផ្តល់ប្រឹក្សា

## សារគន្លឹះ

➢ ធានាឱ្យបានថាអ្នកជំងឺយល់នូវសារសំខាន់ទាំងនេះ

## ចំណុចពិភាក្សា

- កំណត់ត្រាសម្រាប់ការណែនាំកិច្ចពិភាក្សា
- ជំហានសម្រាប់ការតាមដានពេលក្រោយ

## គោះរំលឹកឡើងវិញ

ចំណុចនានាដែលត្រូវណែនាំ ការរំលឹកជាមួយអ្នកជំងឺ

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់ប្រឹក្សា៖

ផ្តល់ឱ្យអ្នកផ្តល់សេវា នូវការណែនាំជាក់លាក់ពីវិធីទំនាក់ទំនង និងការពិភាក្សាជាមួយអ្នកជំងឺ

## កំណត់ត្រា

ប្រាប់អ្នកផ្តល់សេវាពី ទម្រង់សម្រាប់កត់ត្រាការពិភាក្សាជាមួយអ្នកជំងឺ

# របៀបប្រើប្រាស់សៀវភៅមិនបើក

**គោលបំណង៖** គោលបំណងនៃការបង្កើតសៀវភៅបិទបើកនេះឡើង ជាជំនួយអ្នកផ្តល់ប្រឹក្សាដើម្បីណែនាំដល់អ្នករស់នៅជាមួយមេរោគអេដស៍ក្នុងការកំណត់បុគ្គលមួយចំនួន និងបញ្ជូនពួកគាត់ទៅរកសេវាធ្វើតេស្តរកមេរោគអេដស៍។ បុគ្គលទាំងនេះរួមមាន ប្តី/ប្រពន្ធ ដៃគូរួមភេទ ដៃគូប្រើម្ជុលស៊ីរ៉ាំងរួមគ្នា និង/ឬកូនក្នុងបន្ទុក។ សៀវភៅបិទបើកនេះអាចប្រើប្រាស់ក្នុងវគ្គប្រឹក្សាដំបូងទាក់ទងនឹងដំណើរការសេវាតាមរកដៃគូ (PNTT) បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យបញ្ជាក់ថាវិជ្ជមានមេរោគអេដស៍ និងបានចុះឈ្មោះនៅក្នុងសេវា ART ក៏ដូចជានៅវគ្គប្រឹក្សាតាមដានការព្យាបាលជាបន្តបន្ទាប់ក្នុងគោលបំណង (១)ណែនាំដល់អ្នករស់នៅជាមួយមេរោគអេដស៍អំពីសារៈសំខាន់នៃការជូនដំណឹងដល់ដៃគូ លើកទឹកចិត្ត និងកសាងទំនុកចិត្តពួកគាត់ក្នុងការលើកទឹកចិត្តដៃគូមកធ្វើតេស្ត (២) លើកទឹកចិត្តឱ្យគាត់បញ្ចេញឈ្មោះ និងព័ត៌មានរបស់ដៃគូផ្សេងៗ (៣) រៀបចំផែនការជូនដំណឹង និងបញ្ជូនដៃគូមកទទួលសេវា និង (៤) ជួយដល់អ្នកផ្តល់សេវាក្នុងដំណើរការជូនដំណឹង/បញ្ជូនដៃគូ។ សៀវភៅបិទបើកនេះអាចប្រើដោយអ្នកដែលមានគុណវុឌ្ឍច្បាស់លាស់ក្នុងការផ្តល់ការគាំទ្រជូនដំណឹងដល់ដៃគូរួមភេទ ឬដៃគូប្រើម្ជុលសឺរ៉ាំងរួមគ្នារបស់អ្នករស់នៅជាមួយមេរោគអេដស៍។

សូមកត់សម្គាល់ថា PNTT ជាដំណើរការ មិនមែនជាព្រឹត្តិការណ៍មួយដោយឡែកនោះទេ។ ដូច្នេះអ្នកផ្តល់សេវាមិនគួរប្រញាប់រួសរាន់បញ្ចប់ជំហាន ឬមាតិកាទាំងអស់នៅពេលដែលអ្នកជំងឺមិនទាន់ត្រៀមខ្លួនរួចនោះទេ។ អ្វីដែលជាអាទិភាពសម្រាប់អ្នកផ្តល់សេវាគឺការឆ្លើយតបទៅនឹងតម្រូវការបន្ទាន់របស់អ្នកជំងឺក្នុងការទទួលសេវាគាំទ្រ។ នៅពេលខ្លះអ្នកជំងឺដែលមិនយល់ស្របជូនដំណឹងដល់ដៃគូគាត់បន្ទាប់ពីការប្រឹក្សាលើកដំបូង អាចប្តូរចិត្តចូលរួមក្នុងដំណើរការ PNTT នៅពេលក្រោយប្រសិនបើគាត់គិតថាគាត់បានទទួលការគោរព និងយកចិត្តទុកដាក់ពីអ្នកផ្តល់សេវា។ ទោះបីអ្នកជំងឺព្រមចូលរួមក្នុងដំណើរការ PNTT ក៏ដោយ ក៏គាត់ប្រហែលពុំទាន់មានទំនុកចិត្តក្នុងការផ្តល់ព័ត៌មានពីដៃគូរបស់គាត់ភ្លាមៗដែរ។ នៅពេលដែលអ្នកជំងឺមានការជឿជាក់ និងទុកចិត្តលើអ្នកផ្តល់សេវាកាន់តែច្រើន ពួកគាត់អាចនឹងបើកចិត្តផ្តល់ព័ត៌មានបន្ថែមពីដៃគូផ្សេងៗ ឬការដូរដៃគូរបស់គាត់។ ដូច្នេះការផ្តល់សេវា PNTT គួរតែជាផ្នែកមួយនៅក្នុងការប្រាស្រ័យទាក់ទងជាប្រចាំរវាងអ្នកផ្តល់សេវា និងអ្នករស់នៅជាមួយមេរោគអេដស៍។

# របៀបប្រើប្រាស់សៀវភៅបិទបើក

**រចនាសម្ព័ន្ធ៖** សៀវភៅបិទបើកនេះត្រូវបានរៀបចំឡើងដើម្បីអ្នកប្រើប្រាស់ អាចចូលទៅផ្នែកនីមួយៗបានងាយស្រួល។ ផ្នែកនីមួយៗផ្តោតសំខាន់ទៅលើដំហាននៃដំណើរការផ្តល់ប្រឹក្សា ចំពោះសេវាជូនដំណឹង តាមដានដៃគូ និងបញ្ជូនមកធ្វើតេស្ត (PNTT)។ ផ្នែកទី១ ណែនាំពីកំណត់សម្គាល់ របៀបប្រើប្រាស់ និងវិធីសាស្រ្តទំនាក់ទំនងជាមួយអ្នកជំងឺ។ ផ្នែកទី២ ណែនាំអ្នកជំងឺចំពោះការជូនដំណឹងដល់ដៃគូ។ ផ្នែកទី៣ ជួយសម្របសម្រួលការពិភាក្សាស្វែងរកទំនាក់ទំនងរបស់អ្នកជំងឺ និងធ្វើផែនការសម្រាប់ជូនដំណឹង។ ផ្នែកទី៤ ឧបសម្ព័ន្ធសម្រាប់ជាចំណេះដឹងបន្ថែមសម្រាប់អ្នកផ្តល់ប្រឹក្សា។ ប្រធានបទត្រូវបានដាក់កូដពណ៌ជាក់លាក់ សម្រាប់សម្រួលការប្រើប្រាស់។ ផ្នែកនីមួយៗរួមមាន៖

(១) សារសម្រាប់អ្នកផ្តល់សេវា ដើម្បីសម្របសម្រួលការអនុវត្តពិធីសារ PNTT ដោយមានសំណួរ ឬសារគន្លឹះសម្រាប់កិច្ចពិភាក្សា។

(២) សារសម្រាប់អ្នកជំងឺ ដើម្បីប្រើប្រាស់ជាឧបករណ៍សម្រាប់ពិភាក្សាក្នុងអំឡុងពេលផ្តល់ប្រឹក្សា។ សារទាំងនេះអាចមានទម្រង់ជាអក្សរ និងរូបភាពជំនួយ។

**សេចក្តីណែនាំ៖** សៀវភៅបិទបើកនេះគួរដាក់នៅលើតុ ដើម្បីឱ្យអ្នកជំងឺអាចមើលឃើញរូបភាព (នៅមួយចំហៀង) ក្នុងពេលជាមួយគ្នាអ្នកផ្តល់សេវា មើលឃើញសារកំណត់ចំណាំ (នៅមួយចំហៀងទៀត)។ សន្លឹកនីមួយៗមានចំណុចមួយចំនួនដូចខាងក្រោម៖

- ចំណុចគោលសម្រាប់ណែនាំកិច្ចពិភាក្សា
- សារគន្លឹះ ដើម្បីផ្តល់ដល់អ្នកជំងឺ(សរសេរឱ្យបានដិតធំ)
- សារណែនាំសម្រាប់អ្នកផ្តល់សេវា ដោយមានការណែនាំជាក់លាក់ពីវិធីសាស្រ្តល្អៗក្នុងការផ្តល់សារ ឬផ្តល់ប្រឹក្សា
- ប្រអប់សង្ខេបមានសំណួរវាយតម្លៃ ការយល់ដឹងរបស់អ្នកជំងឺអំពីអ្វីដែលទើបបានពិភាក្សាហើយ និងផ្តល់ឱកាសសម្រាប់ប្រើប្រាស់ជំនាញផ្តល់ប្រឹក្សាលើកទឹកចិត្តក្នុងការដោះស្រាយការភាន់ច្រឡំ ឬភាពស្ទាក់ស្ទើរណាមួយរបស់អ្នកជំងឺ
- ប្រអប់កំណត់ត្រា ដែលមានការណែនាំលើការប្រមូលទិន្នន័យ សម្រាប់ការតាមដាន និងរាយការណ៍

ទម្រង់នៃការជូនដំណឹងដៃគូ ក២ អាចប្រើប្រាស់នៅពេលផ្តល់ប្រឹក្សា PNTT ដំបូង ក៏ដូចជានៅពេលជួបបន្តបន្ទាប់ពេលក្រោយ ក្នុងគោលបំណងចងក្រងជាឯកសារការពិភាក្សា។ ទម្រង់នេះគួរបញ្ចូលទៅក្នុងបណ្តុំឯកសារអ្នកជំងឺជាប្រចាំបន្ទាប់ពីវគ្គផ្តល់ប្រឹក្សានីមួយៗបានចប់សព្វគ្រប់។

# របៀបប្រើប្រាស់សៀវភៅបិទបើក

គួរដាក់សៀវភៅបិទបើកនេះនៅលើតុ ដើម្បីឱ្យអ្នកជំងឺអាចមើលឃើញរូបភាព ខណៈពេលដែលអ្នកផ្តល់ប្រឹក្សាមើលផ្នែកដែលមានកំណត់សម្គាល់នៅផ្នែកខាងក្រោយ។ ចំណុចគោលសម្រាប់ណែនាំ( សរសេរដិតច្បាស់ )

**សារគន្លឹះ៖** សារសំខាន់ៗដើម្បីផ្តល់ដល់ទៅអ្នកជំងឺ

**ចំណុចពិភាក្សា៖** ណែនាំការពិភាក្សា និងជំហានដែលបានស្នើឡើង រួមទាំងសំណួរផ្សេងៗ

**ការណែនាំសម្រាប់អ្នកផ្តល់សេវា៖** ការណែនាំជាក់លាក់វិធីសាស្រ្តល្អ និងជំហានក្នុងការផ្តល់សារ ឬផ្តល់ប្រឹក្សា

**តោះរំលឹកឡើងវិញ ៖** មានសំណួរវាយតម្លៃការយល់ដឹងរបស់អ្នកជំងឺ អំពីអ្វីដែលទើបបានពិភាក្សាហើយ និងផ្តល់ឱកាសសម្រាប់ប្រើប្រាស់ជំនាញផ្តល់ប្រឹក្សាលើកទឹកចិត្តក្នុងការដោះស្រាយការភាន់ច្រឡំ ឬភាពស្ទាក់ស្ទើររបស់អ្នកជំងឺ

**កំណត់ត្រា៖** មានការណែនាំលើការប្រមូលទិន្នន័យសម្រាប់ការតាមដាន និងរាយការណ៍

ទម្រង់នៃការជូនដំណឹងដៃគូ ***ក២ អាចប្រើប្រាស់នៅពេលផ្តល់ប្រឹក្សា PNTT ដំបូង*** ក៏ដូចជានៅពេលជួបគ្នាជាបន្តបន្ទាប់ពេលក្រោយក្នុងគោលបំណងចងជាឯកសារការពិភាក្សា។ ទម្រង់នេះគួរបញ្ចូលទៅក្នុងបណ្តុំឯកសាររបស់អតិថិជនជាប្រចាំ បន្ទាប់ពីវគ្គផ្តល់ប្រឹក្សានីមួយៗបានចប់សព្វគ្រប់។

# ការត្រៀមរៀបចំ សម្រាប់ការប្រឹក្សាដែលមានប្រសិទ្ធភាព

- យើងមានជំហានមួយចំនួនដែលអ្នកអាចប្រើ ដើម្បីធានាថាអ្នកជំងឺរបស់អ្នកមានទំនុកចិត្តក្នុងការចែករំលែក ធ្វើផែនការ និងដោះស្រាយបញ្ហាជាមួយអ្នក
- ធានាថាអ្នកនៅទីកន្លែងដែលមានភាពស្ងប់ស្ងាត់ និងឯកជនភាព។ អ្នកជំងឺរបស់អ្នកគួរមានទំនុកចិត្តនិងសុវត្ថិភាពក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់គាត់
- អង្គុយទល់មុខអ្នកជំងឺ និងប្រើខ្សែភ្នែកជាមួយគាត់ឱ្យបានសមស្រប
- និយាយឱ្យបានច្បាស់ ប្រើសំដីទន់ភ្លន់ និងប្រើពាក្យដែលអ្នកជំងឺងាយស្រួលយល់
- គោរពសិទ្ធិអ្នកជំងឺក្នុងការជ្រើសរើស និងចៀសវាងការវិនិច្ឆ័យ ការស្តីបន្ទោស ឬការរិះគន់ទាំងឡាយ
- ធានាថាអ្នកពន្យល់ពីដែនកំណត់នៃការថែរក្សាការសម្ងាត់ឱ្យបានច្បាស់លាស់។ អ្នកនឹងមិនប្រាប់ព័ត៌មានរបស់អ្នកជំងឺទៅអ្នកដទៃដាច់ខាត លុះត្រាតែអ្នកបារម្ភអំពីសុខភាពរបស់ពួកគាត់ សុវត្ថិភាព ឬសុខភាព និងសុវត្ថិភាពចំពោះអ្នកដទៃ
- កុំវិនិច្ឆ័យចំណេះដឹងរបស់អ្នកជំងឺ។ មុននឹងអ្នកផ្តល់ព័ត៌មាន គួរសួរនាំតើពួកគាត់ធ្លាប់បានដឹងអ្វីខ្លះរួចមកហើយ។ នៅពេលអ្នកបង្ហាញអំពីព័ត៌មានថ្មី ឈប់ឬពន្យារពេលឱ្យបានញឹកញាប់ និងសួរដើម្បីប៉ាន់ស្មានកម្រិតផាសុកភាព និងការយល់ដឹងរបស់អ្នកជំងឺអំពីសារដែលបានផ្តល់ឱ្យ។



**ផ្តោតសំខាន់ទៅលើតម្រូវការ និងការលើកទឹកចិត្តដល់អ្នកជំងឺ**

# ជំនាញទំនាក់ទំនង និងការផ្តល់ប្រឹក្សាលើកទឹកចិត្ត

ជំនាញប្រាស្រ័យទាក់ទង ពិតជាមានសារៈសំខាន់ក្នុងការគាំទ្រដល់អ្នកជំងឺនៅពេលចាប់ផ្តើមការព្យាបាលដំបូង និងទទួលការព្យាបាលបន្ត។ ប្រើជំនាញផ្តល់ប្រឹក្សាលើកទឹកចិត្ត(ដូចខាងក្រោម) នៅពេលសមស្រប(រួមទាំងឧទាហរណ៍ភាសាដែលគួរប្រើ)៖

**ក. ប្រើសំណួរបើក** (ប្រើសំណួរបើកដើម្បីស្វែងរកព័ត៌មាន និង ស្វែងយល់ អំពីការយល់ឃើញរបស់អ្នកជំងឺ)

- តើបញ្ហាអ្វីខ្លះដែលធ្វើឱ្យអ្នកលំបាកក្នុងការជូនដំណឹងទៅដៃគូរបស់អ្នក?
- តើអ្នកអាចធ្វើដូចម្តេចខ្លះ ដើម្បីជំនះការលំបាកទាំងនោះ?
- តើអ្នកគិតថានឹងអាចមានបញ្ហាអ្វីកើតឡើងប្រសិនបើអ្នកត្រូវនិយាយរឿងនេះជាមួយដៃគូរបស់អ្នក?

**ខ. ការបញ្ជាក់ចំណុចវិជ្ជមាន**

(ស្គាល់អំពីសញ្ញា ឬចំណុចវិជ្ជមាន និងគុណតម្លៃរបស់អ្នកជំងឺ ដើម្បីធ្វើការគាំទ្រ និងលើកទឹកចិត្ត)

- អ្វីដែលគួរឱ្យសរសើរអំពីអ្នកគឺថាអ្នកនិយាយត្រង់អំពីការលេបថ្នាំប្រឆាំងមេរោគអេដស៍ (ARV) របស់អ្នក
- អ្នកជាមនុស្សច្បាស់លាស់ក្នុងការគ្រប់គ្រងនូវរាល់ឧបសគ្គទាំងឡាយ
- អ្នកពិតជាព្យាយាមខ្លាំងក្នុងការជូនដំណឹងទៅដៃគូពីការធ្វើតេស្តរកមេរោគអេដស៍ ទោះជាអ្នកជួបឧបសគ្គច្រើនយ៉ាងណាក៏ដោយ

**គ. ស្តាប់ដោយឆ្លុះបញ្ចាំង** (ប្រើពាក្យ "អ្នក" ក្នុងប្រយោគ ស្តាប់ អង្កេត និងបកប្រែសញ្ញាដែលអ្នកជំងឺមិនបាននិយាយ ដើម្បីប្រមូលព័ត៌មាន ណែនាំការពិភាក្សា និងលើកទឹកចិត្តអ្នកជំងឺក្នុងការផ្លាស់ប្តូរ)

- អ្នកឆ្ងល់ថាតើនឹងមានអ្វីកើតឡើងប្រសិនបើអ្នកលេបថ្នាំប្រឆាំងមេរោគអេដស៍ (ARV)
- អ្វីដែលខ្ញុំបានឮអ្នកនិយាយថាអ្នកកំពុងប្រឬកប្រឬលខ្លាំង ធ្វើឱ្យអ្នកគិតថាសុខភាពរបស់អ្នកគ្រាន់តែជាបញ្ហាតិចតួចប៉ុណ្ណោះក្នុងពេលនេះ
- អ្នកចង់ចាប់ផ្តើមទទួលការព្យាបាល ប៉ុន្តែអ្នកបារម្ភខ្លាចដៃគូរបស់អ្នកដឹងថាអ្នករស់នៅជាមួយមេរោគអេដស៍។ អ្នកចង់ប្រាប់ដៃគូ ប៉ុន្តែនេះមិនមែនជាអ្វីដែលអ្នកចង់ប្រាប់ឥឡូវនេះទេ

# ជំនាញទំនាក់ទំនង និងការផ្តល់ប្រឹក្សាលើកទឹកចិត្ត

## ឃ. សង្ខេបនៃការសន្ទនា

(ធ្វើការសង្ខេបជាការកាត់សម្គាល់ ប្រើសំណួរបើក ធ្វើការឆ្លុះបញ្ចាំង និងគាំទ្រចំណុចវិជ្ជមានរបស់អ្នកជំងឺ)

➢ អ្នកកំពុងជួបការលំបាកក្នុងការនិយាយទៅកាន់ដៃគូពីការធ្វើតេស្តរកមេរោគអេដស៍ តែអ្នកបានយល់ផងដែរពីសារសំខាន់នៃការធ្វើតេស្ត និងអាចនិយាយដោយយកហេតុថា អ្នកចង់ឱ្យដៃគូមានសុខភាពល្អ មិនចង់បាត់បង់មនុស្សជាទីស្រលាញ់ ឬ អ្នកមិនចង់ឱ្យកូនរបស់អ្នកឆ្លងមេរោគអេដស៍នោះទេ។

➢ អ្នកហាននិយាយទៅកាន់ដៃគូ ហើយត្រូវការពេលវេលាមួយសមស្រប.... សូមជួយបំពេញចំណុចខ្វះខាតដែលខ្ញុំមិនបានរៀបរាប់ខាងលើ?

## ខ. សួរ -ប្រាប់-សួរ

(សួរអ្វីដែលអ្នកជំងឺដឹង សុំការអនុញ្ញាតផ្តល់ព័ត៌មានថ្មី និងសួរបញ្ជាក់ពីការយល់ឃើញរបស់គាត់ចំពោះព័ត៌មានថ្មីនោះ)

➢ខ្ញុំសុំសួរអ្នកជាមុនសិន ថាតើអ្នកធ្លាប់បានឮអ្វីខ្លះពីព័ត៌មានស្តីពីការជូនដំណឹងទៅដៃគូពីការធ្វើ តេស្តរកមេរោគអេដស៍?

➢យើងរកឃើញពីវិធីសាស្ត្រជាច្រើនដែលមានប្រសិទ្ធភាពក្នុងការនិយាយទៅកាន់ដៃគូរបស់អ្នកអំពីបញ្ហានេះ

➢តើអ្នកចង់ដឹងបន្ថែមអំពីចំណុចនេះដែរឬទេ?

➢ខ្ញុំយល់អំពីអារម្មណ៍របស់អ្នកដែលខ្វល់ខ្វាយពីប្រតិកម្មរបស់ដៃគូរបស់អ្នកនៅពេលដែលគាត់ដឹង។ មានមនុស្សជាច្រើនមានអារម្មណ៍ដូចគ្នា នៅពេលដែលពួកគាត់ជួបបញ្ហានេះដំបូង។ តែគាត់អាចពិចារណា និងផ្លាស់ប្តូរការគិតនៅពេលទទួលបានព័ត៌មានត្រឹមត្រូវពីបញ្ហានេះ

➢តើអ្នកគិតដូចម្តេចដែរអំពីយោបល់ទាំងនេះ?

## ច. ភាសាសម្គាល់អំពីការផ្លាស់ប្តូរឥរិយាបទ

(សួរបញ្ជាក់ពីចំណង់ សមត្ថភាព ហេតុផល តម្រូវការ ផែនការ ឬការប្តេជ្ញាចិត្ត នៅពេលដែលអ្នកជំងឺបង្ហាញពីការតាំងចិត្តនឹងធ្វើសកម្មភាព និងប្តេជ្ញាចិត្តដើម្បីផ្លាស់ប្តូរ)

➢ នៅពេលអ្នកជំងឺបង្ហាញបំណងប្រាថ្នា(ក្តីសង្ឃឹម ការចង់បាន) សមត្ថភាព មូលហេតុ តម្រូវការ ផែនការ ឬឆន្ទៈក្នុងការផ្លាស់ប្តូរ

ឧទា: ខ្ញុំចង់និយាយរឿងនេះជាមួយគាត់ណាស់ ដើម្បីឆាប់បានដឹងពីស្ថានភាពរបស់គាត់

## ឆ. ការវាស់វែងអំពីការផ្លាស់ប្តូរ ឬទំនុកចិត្ត

(ដោយប្រើការឆ្លុះបញ្ចាំង បញ្ជាក់ចំណុចវិជ្ជមាន លើកជាឧទាហរណ៍ និងធ្វើការសង្ខេបដោយប្រើបន្ទាត់វាស់វែងលើភាពជឿជាក់/សារៈសំខាន់ សួរសំណួរអំពីចំណង់ សមត្ថភាព តម្រូវការ ឬមូលហេតុនៃការផ្លាស់ប្តូរ)

➢ ប្រើឧបករណ៍បន្ទាត់វាស់វែងសារៈសំខាន់ ឬទំនុកចិត្តឱ្យបានសមស្រប សួរសំណួរអំពីបំណងប្រាថ្នា សមត្ថភាព តម្រូវការ ឬហេតុផលក្នុងការផ្លាស់ប្តូរ

ឧទា:តើអ្នកតាំងចិត្តកម្រិតណាក្នុងការយករឿងនេះទៅនិយាយជាមួយ ដៃគូ? (ប្រើបន្ទាត់)

# ប្រការគួរធ្វើ និង មិនគួរធ្វើរបស់អ្នកផ្តល់ប្រឹក្សា

## គួរធ្វើ

- ☑ ប្រើសំណួរបើក ដើម្បីស្វែងយល់ពីចំណេះដឹង បទពិសោធន៍ និងបញ្ហាប្រឈមរបស់អ្នកជំងឺ
- ☑ ទាញយក និងជំរុញកត្តាខាងក្នុងរបស់អ្នកជំងឺក្នុងការផ្លាស់ប្តូរ
- ☑ ស្វែងរកមូលហេតុដែលអ្នកជំងឺមាន ដោយទទួលស្គាល់នូវភាពខុសគ្នា និងធ្វើការផ្លាស់ប្តូរដោយផ្តោតលើការសម្រេចចិត្តរបស់អ្នកជំងឺ
- ☑ ប្រើជំនាញឆ្លុះបញ្ចាំងអារម្មណ៍ ឬជំនាញឆ្លុះបញ្ចាំងទាំងសងខាង ដើម្បីឆ្លើយតបទៅនឹងការយល់ផ្ទុយគ្នានេះ
- ☑ ជួយអ្នកជំងឺឱ្យចូលរួមក្នុងការដោះស្រាយបញ្ហារបស់គាត់
- ☑ ផ្តោតលើការសម្រេចចិត្តរបស់អ្នកជំងឺក្នុងការថែទាំសុខភាពរបស់គាត់

## មិនគួរធ្វើ

- ☒ សន្មត់ថាអ្នកដឹងពីបញ្ហាគ្រប់យ៉ាងរបស់ពួកគាត់ ជាងពួកគាត់ដឹងពីខ្លួនឯង
- ☒ ប្រាប់អ្នកជំងឺឱ្យផ្លាស់ប្តូរ ឬជំរុញពួកគាត់ឱ្យយល់ព្រមកែប្រែ នៅពេលពួកគាត់មិនទាន់បានត្រៀមខ្លួន
- ☒ ឈ្លោះជាមួយអ្នកជំងឺប្រសិនបើពួកគេមិនយល់ព្រមផ្លាស់ប្តូរតាមខ្លួនចង់បាន
- ☒ បញ្ជាអ្នកជំងឺថាពួកគាត់ត្រូវធ្វើនេះ ឬធ្វើនោះទាំងពួកគាត់មិនពេញចិត្តនឹងធ្វើវា
- ☒ ស្តីបន្ទោស បញ្ជើចបញ្ជើ ឬមើលងាយអ្នកជំងឺ ព្រោះតែអ្នកមិនយល់ព្រមជាមួយជម្រើសរបស់ពួកគាត់

# តើយើងអាចពិភាក្សាពីរឿងនេះបានទេ ?



# ជំហានទី១៖ ប្រាប់ទៅអ្នកជំងឺអំពីសេវាតាមរកដៃគូដល់អ្នកជំងឺតម្រុយ

## ក. កិច្ចស្វាគមន៍ និងធ្វើកិច្ចព្រមព្រៀងផ្ទាល់មាត់




### សារគន្លឹះ

តាមរយៈការជជែកពិភាក្សាជាមួយខ្ញុំ អ្នកកំពុងជួយការពារមនុស្សជាទីស្រលាញ់របស់អ្នក

- តួនាទីរបស់ខ្ញុំគឺជួយអ្នកក្នុងការការពារដៃគូ និងក្រុមគ្រួសាររបស់អ្នក
- ការជួបគ្នានេះផ្ដោតសំខាន់ទៅលើអ្នក។ រាល់សំណួរទាំងឡាយដែលខ្ញុំមិនអាចឆ្លើយបាន យើងនឹងធ្វើការស្វែងរកចម្លើយទាំងអស់គ្នា
- វាអាស្រ័យលើអ្នកក្នុងការយល់ព្រម ឬមិនយល់ព្រមពិភាក្សាពីរឿងនេះ

### កំណត់ត្រា

កត់ត្រាក្នុងទម្រង់ក២ ថាអ្នកជំងឺយល់ព្រម ឬមិនយល់ព្រមពីសេវាជូនដំណឹងដៃគូ

### ចំណុចពិភាក្សា

សូមអរគុណអ្នកខ្លាំងណាស់ ចំពោះការមកពិភាក្សាជាមួយខ្ញុំក្នុងថ្ងៃនេះ។ ការចំណាយពេលរបស់អ្នកក្នុងការមកជួបខ្ញុំ បង្ហាញថាអ្នកចង់ជួយការពារមនុស្សជាទីស្រលាញ់របស់អ្នកពីមេរោគអេដស៍។

- ខ្ញុំឈ្មោះ __________ ខ្ញុំមាន[តួនាទី] .................. ធ្វើការនៅ.................... [ឈ្មោះទីកន្លែង]
- ប៉ុន្តែ មុននឹងយើងចាប់ផ្ដើម ខ្ញុំចង់ដឹងថាតើអ្នកមានអារម្មណ៍យ៉ាងណាចំពោះរោគវិនិច្ឆ័យរបស់អ្នក?
- តើការរំពឹងទុករបស់អ្នកចំពោះការពិភាក្សារបស់យើងក្នុងថ្ងៃនេះ ចង់បានអ្វី?
- ខ្ញុំចង់ពិភាក្សាជាមួយអ្នកក្នុងថ្ងៃនេះ អំពីការជូនដំណឹងដល់ដៃគូរបស់អ្នក។ តួនាទីរបស់ខ្ញុំគឺជួយអ្នកក្នុងការធានាថា ដៃគូរបស់អ្នកនឹងដឹងអំពីស្ថានភាពមេរោគអេដស៍របស់គាត់។
- គ្រប់យ៉ាងដែលយើងពិភាក្សាក្នុងថ្ងៃនេះគឺទុកជាការសម្ងាត់
- អ្នកអាចសួរសំណួរទាំងឡាយដែលអ្នកចង់ដឹង។ បើខ្ញុំមិនអាចផ្ដល់ចម្លើយបានក្នុងថ្ងៃនេះ ខ្ញុំនឹងស្វែងរកវានៅពេលក្រោយសម្រាប់អ្នក
- តើយើងអាចពិភាក្សាពីរឿងនេះបានដែរឬទេ?

# យើងត្រូវការកិច្ចសហការពីអ្នក!

- ដៃគូ និងកូនរបស់អ្នកក៏អាចប្រឈមនឹងការឆ្លងមេរោគអេដស៍ដែរ
- ពួកគេត្រូវធ្វើតេស្តរកមេរោគអេដស៍
- អ្នកអាចជួយដើម្បីធានាសុវត្ថិភាព និងផាសុកភាព តាមរយៈការជូនដំណឹង ឬការផ្តល់ព័ត៌មានដល់ពួកគេ
- យើងអាចជួយអ្នកបាន!



# ជំហានទី១៖ ប្រាប់ទៅអ្នកជំងឺអំពីសេវាតាមរកដៃគូដល់អ្នកជំងឺតម្រុយ

## ខ.ប្រាប់ទៅអ្នកជំងឺអំពីសេវាតាមរកដៃគូ និងសារៈសំខាន់




### សារគន្លឹះ

ការផ្តល់ដំណឹងដល់ដៃគូរបស់អ្នក មាននន័យថាជាការទាក់ទងដៃគូ និងកូនរបស់អ្នក និងបញ្ជូនពួកគាត់មកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍

- ការជូនដំណឹងដល់ដៃគូ និងកូនរបស់អ្នកគឺជួយពួកគាត់ឱ្យមានសុវត្ថិភាព និងសុខភាពល្អ បើទោះបីលទ្ធផលមេរោគអេដស៍វិជ្ជមាន ឬអវិជ្ជមានក៏ដោយ
- ការពិភាក្សាអំពីមេរោគអេដស៍ជាមួយដៃគូ អាចជាការលំបាក ប៉ុន្តែយើងអាចជួយអ្នកបាន

### សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

**កត់ត្រាភាសាដែលមានទំនោរទៅរកការផ្លាស់ប្តូរទាក់ទងនឹងការជូនដំណឹងដល់ដៃគូ៖**

- ឆ្លុះបញ្ចាំងភាសារបស់អ្នកជំងឺអំពីទំនោរទៅរកការផ្លាស់ប្តូរ
- សួររកការពន្យល់បន្ថែម
- សួររកឧទាហរណ៍បញ្ជាក់

### ដោះរំលឹកឡើងវិញ

- តើអ្នកយល់យ៉ាងណាចំពោះការជូនដំណឹងដល់ដៃគូ?
- តើដៃគូរបស់អ្នករួមមានអ្នកណាខ្លះ?
- ហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់ដៃគូ និងកូនរបស់អ្នកមកធ្វើតេស្ត? តើវាមានសារៈប្រយោជន៍អ្វីខ្លះ?

### ចំណុចពិភាក្សា

- តើអ្នកដឹងអ្វីខ្លះពីការជូនដំណឹងទៅដៃគូ? ហេតុអ្វីបានជាមានសារៈសំខាន់?
- វាជាការសំខាន់ដែលដៃគូរួមភេទ ឬដៃគូប្រើម្ជុលសឺរ៉ាំងរួមគ្នារបស់អ្នក និងកូនរបស់អ្នកដឹងអំពីស្ថានភាពរបស់ពួកគាត់៖
  - ✓ ប្រសិនបើពួកគាត់មានមេរោគអេដស៍ គាត់អាចចាប់ផ្តើមទទួលការព្យាបាលដើម្បីថែរក្សាសុខភាព និងកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ទៅអ្នកដទៃ។
  - ✓ ប្រសិនបើពួកគេមិនមានមេរោគអេដស៍ទេ យើងអាចផ្តល់សេវាក្នុងការជួយធានាថាពួកគេនៅតែមិនមានឆ្លងមេរោគអេដស៍។
- និយាយជាមួយអ្នកដៃគូអំពីមេរោគអេដស៍អាចជាការលំបាក ប៉ុន្តែយើងអាចជួយបាន។ ប្រសិនបើអ្នកយល់ព្រម យើងនឹង៖
  - ✓ បង្កើតបញ្ជីឈ្មោះដៃគូ/កូនរបស់អ្នកទាំងអស់
  - ✓ ជួយអ្នកក្នុងការសម្រេចចិត្ត តើត្រូវទាក់ទងពួកគាត់ដោយរបៀបណា
  - ✓ ភ្ជាប់ដៃគូ ឬកូនរបស់អ្នកទៅសេវាធ្វើតេស្ត និងសេវាដ៏ទៃទៀតប្រសិនបើចាំបាច់
- ពីកម្រិត ១ ដល់ ១០ តើវាមានសារៈសំខាន់កម្រិតណាសម្រាប់អ្នកក្នុងការការពារដៃគូ/កូនរបស់អ្នកពីមេរោគអេដស៍? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វីខ្លះដែលអ្នកគិតថាការជូនដំណឹងទៅពួកគាត់មានសារៈសំខាន់?
- ពីកម្រិត ១ ដល់ ១០ តើអ្នកមានទំនុកចិត្តខ្លាំងប៉ុណ្ណាក្នុងការបញ្ជូនដៃគូរបស់អ្នកទៅធ្វើតេស្ត? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យអ្នកមានទំនុកចិត្តខ្ពស់បែបនេះ?

# យើងនឹងរក្សាការសម្ងាត់
# នូវអ្វីៗដែលបានពិភាក្សាគ្នា !






# ជំហានទី១៖ ប្រាប់ទៅអ្នកជំងឺអំពីសេវាតាមរកដៃគូដល់អ្នកជំងឺតម្រុយ

## គ.យើងនឹងរក្សាការសម្ងាត់




### សារគន្លឹះ

- យើងនឹងរក្សាការសម្ងាត់របស់អ្នក
- មិនមានអ្វីកើតឡើងឡើយបើគ្មានការយល់ព្រមពីអ្នក

### សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

**លើកទឹកចិត្តអ្នកជំងឺក្នុងការទទួលសេវាជូនដំណឹងដៃគូតាមរយៈការសង្ខេបភាសាទំនោរទៅរកការផ្លាស់ប្តូរ៖**

- ហេតុអ្វីគាត់និយាយថាការជូនដំណឹងមានសារៈសំខាន់?
- តើអ្វីដែលធ្វើឱ្យគាត់មានទំនុកចិត្តគឺថាគាត់អាចធ្វើបាន?

**កុំបង្ខំ ប្រសិនបើអ្នកជំងឺមិនទាន់រៀបចំខ្លួនហើយ ត្រូវលើកទឹកចិត្ត និងផ្តោតលើការជឿជាក់លើខ្លួនឯង។**

- ឥឡូវនេះ វាហាក់ដូចជាមិនមែនជាអាទិភាពសម្រាប់អ្នកទេ។ តើវិធីអ្វីដែលអាចធ្វើឱ្យអ្នកអាចជូនដំណឹងដល់ដៃគូរបស់អ្នកនៅពេលខាងមុខ?

### ចំណុចពិភាក្សា

- រាល់ពាក្យពេចន៍ដែលយើងនិយាយគ្នានៅពេលនេះ នឹងត្រូវបានរក្សាជាការសម្ងាត់
  - ✓ យើងនឹងមិនទាក់ទងទៅដៃគូរបស់អ្នកទេ បើគ្មានការអនុញ្ញាតពីអ្នក
  - ✓ យើងនឹងមិនប្រាប់ឈ្មោះ ឬលទ្ធផលតេស្តរបស់អ្នកទៅដៃគូរបស់អ្នកទេ បើគ្មានការយល់ព្រមពីអ្នក
  - ✓ បើអ្នកបញ្ជូននរណាម្នាក់មកធ្វើតេស្ត យើងក៏នឹងមិនប្រាប់អ្នកថា ពួកគេបានធ្វើតេស្ត ឬអត់ ឬលទ្ធផលតេស្តយ៉ាងដូចម្តេចនោះដែរ
- អ្នកនៅតែទទួលការថែទាំដូចអ្នកដ៏ទៃដែរ បើទោះជាអ្នកជ្រើសរើសមិនចូលរួមក្នុងសេវាជូនដំណឹងដល់ដៃគូក៏ដោយ
- នៅពេលខ្ញុំលើកឡើងប្រធានបទនៃការជូនដំណឹងដល់ដៃគូ អ្នកបាននិយាយថាអ្នកមានអារម្មណ៍ [សង្ខេបភាសាទំនោរទៅរកការផ្លាស់ប្តូររបស់អ្នកជំងឺនៅទីនេះ]
- មុននឹងបន្តដំណើរការពិភាក្សាទៅមុខទៀត យើងចង់ឱ្យប្រាកដថាអ្នកបានយល់ព្រមបន្តទៀត

# តើអ្នកធ្លាប់ប្រព្រឹត្តទង្វើប្រឈមទាំងនេះទេ?




រួមភេទជាមួយ
អ្នកផ្ទុកមេរោគអេដស៍



មានដៃគូ ៤នាក់ ឬ
ច្រើនជាង



រួមភេទជាមួយភេទដូចគ្នា
ឬ អ្នកប្លែងភេទ



ធ្វើចំណាកស្រុក
ទៅធ្វើការ



ប្រើសារធាតុញៀន



ចាក់សារធាតុញៀន



ឱ្យ ឬទទួលលុយ
ពីសេវារួមភេទ

# ជំហានទី២៖ ការស្រាវជ្រាវកត្តាប្រឈមរបស់អ្នកជំងឺ (កត់ត្រាការប្រឈម)




## សារគន្លឹះ

- ការយល់ដឹងពីទង្វើរបស់អ្នកជួយយើងក្នុងការស្វែងរកអ្នកដទៃទៀតដែលយើងអាចនឹងត្រូវធ្វើតេស្ត
- ការចែករំលែកព័ត៌មាននេះ បង្ហាញថាអ្នកចង់ធ្វើទង្វើដែលត្រឹមត្រូវ និងការពារសុខភាពរបស់អ្នកដទៃ

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

ចងចាំថា អ្នកជំងឺអាចមានកត្តាប្រឈមច្រើន។ លើកទឹកចិត្តអ្នកជំងឺឱ្យពិចារណាទង្វើទាំងឡាយដែលគាត់ធ្លាប់ប្រព្រឹត្ត

## កំណត់ត្រា

កត់ត្រាឥរិយាបថប្រឈមឱ្យបានដាក់លាក់ក្នុងទម្រង់ក២ពីកត្តាប្រឈមរបស់អ្នកជំងឺឱ្យបានត្រឹមត្រូវ

## ចំណុចពិភាក្សា

- មុននឹងចាប់ផ្តើមនិយាយអំពីដៃគូរបស់អ្នក ខ្ញុំចង់ដឹងបន្តិចអំពីអ្នក និងអ្វីដែលអាចធ្វើឱ្យអ្នកប្រឈមនឹងការឆ្លងមេរោគអេដស៍
- សំណួរទាំងនេះនឹងជួយយើងក្នុងការកំណត់ថាអ្នកណាដែលយើងអាចទាក់ទងក្នុងការធ្វើតេស្តរកមេរោគអេដស៍
- សូមចងចាំថា រាល់អ្វីដែលអ្នកចែករំលែកជាមួយខ្ញុំគឺត្រូវបានរក្សាជាការសម្ងាត់
- រូបភាពទាំងនេះបង្ហាញពីឥរិយាបថទាំងឡាយ ដែលអាចធ្វើឱ្យមនុស្សម្នាក់ប្រឈមនឹងការឆ្លងមេរោគអេដស៍ ឬចម្លងមេរោគអេដស៍ទៅអ្នកដទៃ។ តើមួយណាដែលអ្នកធ្លាប់បានប្រព្រឹត្តកន្លងមក?
  - ✓ សូមប្រាប់ខ្ញុំបន្ថែមអំពីឥរិយាបថនោះបានទេ
  - ✓ តើការប្រព្រឹត្តនេះកើតឡើងញឹកញាប់ដែរឬទេ? មានដៃគូប៉ុន្មាននាក់?
  - ✓ តើវាកើតឡើងចុងក្រោយនៅពេលណា? ច្រើន ឬតិចជាង៦ខែ?
- ចុះឥរិយាបថផ្សេងទៀតមានទេ?

# នរណាខ្លះដែលជាអ្នកកំពុងប្រឈម?



យើងត្រូវដឹងពី ដៃគូរួមភេទរបស់អ្នក



អ្នកដែលបាន ប្រើម្ជុលស៊ីរ៉ាំងរួមគ្នា



កូនរបស់អ្នក

✓ អ្នកអាចជួយពួកគាត់បាន តាមរយៈ ការចែករំលែកព័ត៌មាននេះ

✓ វាអាស្រ័យទៅលើអ្នក ខ្ញុំនឹងមិន ទាក់ទងពួកគាត់នោះទេ ប្រសិនបើ មិនមានការអនុញ្ញាតពីអ្នកជាមុន

# ជំហានទី៣៖ កត់ត្រាឈ្មោះដៃគូរួមភេទ និងអ្នកពាក់ព័ន្ធទាំងអស់




## សារគន្លឹះ

- ដៃគូរួមភេទ ឬដៃគូប្រើម្ជុលស៊ីរ៉ាំងរួមគ្នា និងកូនអ្នក អាចឆ្លងមេរោគអេដស៍ និងចាំបាច់ត្រូវធ្វើតេស្ត
- តាមរយៈការចែករំលែកព័ត៌មាននេះ អ្នកកំពុងជួយការពារពួកគាត់

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

អ្នកជំងឺជាច្រើន មានដៃគូរួមភេទលើសពីម្នាក់ មិនត្រូវបញ្ឈប់ការពិភាក្សាពីដៃគូផ្សេងទៀត នៅពេលអ្នកដឹងថាគាត់មានប្តី/ប្រពន្ធ ឬដៃគូជាប់លាប់រួចហើយ។ ត្រឡប់ទៅមើលការវាយតម្លៃកម្រិតប្រឈមនៅជំហានមុន

## កំណត់ត្រា

កត់ត្រាព័ត៌មានដៃគូក្នុងទម្រង់ ក២ គួរចាំថាប្រើប្រអប់ផ្សេងគ្នាចំពោះដៃគូផ្សេងគ្នា។

## ចំណុចពិភាក្សា

- មានសារៈសំខាន់ដែលយើងកត់ត្រាដៃគូរបស់អ្នកដែលអាចឆ្លងមេរោគអេដស៍ ដូចជា៖
  - ✓ ដៃគូរួមភេទទាំងអស់ក្នុងរយៈពេល ៦ ខែចុងក្រោយ ឬលើសពីនេះ
  - ✓ ដៃគូដែលធ្លាប់ចាក់ម្ជុលស៊ីរ៉ាំងរួមគ្នាទាំងអស់ (ទោះជាមិនមែនក្នុងគោលបំណងក្នុងការព្យាបាល ក៏ដោយ)
  - ✓ កូនបង្កើតដែលមានអាយុក្រោម១៥ឆ្នាំ
- សូមចងចាំថា បុគ្គលទាំងនេះត្រូវធ្វើតេស្តរកមេរោគអដស៍។ តាមរយៈការចែករំលែកព័ត៌មាននេះ អ្នកកំពុងជួយការពារពួកគាត់
- សម្រាប់ដៃគូនីមួយៗ យើងត្រូវការឈ្មោះ អាយុ និងភេទរបស់គាត់ ព្រមទាំងសម្ព័ន្ធភាពរវាងអ្នកជាមួយពួកគាត់
- ប្រសិនបើមាន យើងក៏ត្រូវការផងដែរនូវអាសយដ្ឋាន និងលេខទូរស័ព្ទ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់គាត់។ យើងនឹងមិនទាក់ទងអ្នកទាំងនោះ បើគ្មានការអនុញ្ញាតពីអ្នក។

# កិច្ចការចម្បងរបស់យើង
# គឺការពារសុវត្ថិភាពរបស់អ្នកពីអំពើហិង្សា



តើដៃគូណាខ្លះ ដែលអ្នកទើបប្រាប់ខ្ញុំពីលើកមុនដែលគាត់ធ្លាប់ប្រព្រឹត្តដូចខាងក្រោម៖

- ✓ វាយ ទាត់ ទះ ឬប្រើអំពើហិង្សាលើរាងកាយអ្នក?
- ✓ គំរាមកំហែងអ្នក?
- ✓ បង្ខំអ្នកឱ្យរួមភេទ ឬធ្វើសកម្មភាពផ្លូវភេទដែលអ្នកមិនចង់?

ចំណុចទាំងអស់ខាងលើនេះគឺជាអំពើហិង្សា។ ប្រសិនបើអ្នកធ្លាប់រងគ្រោះនូវអំពើហិង្សាពីដៃគូ យើងអាចពិភាក្សាអំពីសេវាគាំទ្រនានា ហើយអ្នកអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន

# ជំហានទី៤៖ ការស្រាវជ្រាវរកដៃគូបង្កអំពើហិង្សា




## សារគន្លឹះ

- សុវត្ថិភាពអ្នកជំងឺជាកត្តាចម្បង
- យើងនឹងមិនទាក់ទងដៃគូរបស់អ្នកទេ ប្រសិនបើមានការគំរាមកំហែង ហើយអំពើហិង្សាអាចនឹងកើតមានដល់អ្នក។
- បើអ្នកជាជនរងគ្រោះដោយអំពើហិង្សា យើងអាចពិភាក្សាអំពីសេវាគាំទ្រនានាដែលអ្នកអាចជ្រើសរើសបាន ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នក ព្រមទាំងអាចណែនាំ និងផ្សាភ្ជាប់ទៅនឹងសេវាសំខាន់ៗដែលអ្នកត្រូវការ

## សេចក្ដីណែនាំសម្រាប់អ្នកផ្ដល់សេវា

កាតព្វកិច្ចដំបូងរបស់យើងគឺ មិនបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ ដើម្បីការពារសុវត្ថិភាពរបស់គាត់ដែលមានដៃគូអាចប្រើអំពើហិង្សា ដែលនឹងត្រូវបញ្ឈប់ពីសេវាតាមដានរកដៃគូ។ អ្នកផ្ដល់សេវាមានកាតព្វកិច្ចផ្ដល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយអំពីសេវាសំខាន់ៗពាក់ព័ន្ធនឹងអំពើហិង្សាដល់អ្នកជំងឺ បើទោះជាគាត់បង្ហាញ ឬមិនបានបង្ហាញថា គាត់គឺជាជនរងគ្រោះដោយអំពើហិង្សាពីដៃគូក៏ដោយ

## កំណត់ត្រា

កត់ត្រាព័ត៌មានអំពីហិង្សារបស់អ្នកជំងឺក្នុងទម្រង់**ក២** បើដៃគូមិនបានជូនដំណឹងដោយសារបញ្ហាហិង្សាជ្រើសរើស "ពន្យារពេលដោយសារ IPV"

## ចំណុចពិភាក្សា

- កិច្ចការសំខាន់បំផុតរបស់ខ្ញុំគឺការពារសុខភាព និងសុវត្ថិភាពរបស់អ្នក
- ចំពោះដៃគូដែលអ្នកទើបប្រាប់ខ្ញុំពីមុន តើដៃគូណាខ្លះដែលគាត់ធ្លាប់៖
  - ✓ វាយ ទាត់ ទះ ឬ ប្រើអំពើហិង្សាលើរាងកាយអ្នក?
  - ✓ គំរាមកំហែងអ្នក ?
  - ✓ បង្ខំអ្នកឱ្យរួមភេទ ឬ ធ្វើសកម្មភាពផ្លូវភេទដែលអ្នកមិនចង់ ?
- យើងនឹងមិនទាក់ទងពួកគេផ្ទាល់ទេ ប្រសិនបើយើងមិនអាចធានាសុវត្ថិភាពរបស់អ្នកបាន
- មិនមាននរណាម្នាក់ គួរក្លាយជាគោលដៅនៃអំពើហិង្សា ឬត្រូវបានបង្ខំឱ្យជូនដំណឹងទៅដៃគូនោះឡើយ។ ប្រសិនបើអ្នក ចង់ចែករំលែកពីភាពរងគ្រោះរបស់អ្នកដោយអំពើហិង្សា និង/ឬចង់ឱ្យខ្ញុំភ្ជាប់អ្នកទៅសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សា ខ្ញុំអាចណែនាំអំពីសេវាទាំងនោះដល់អ្នកបាន។ សូមប្រើឧបសម្ព័ន្ធទី១ នៅទំព័រខាងក្រោយសម្រាប់បន្តជំហានសំខាន់ៗដើម្បីប៉ាន់ប្រមាណ និងឆ្លើយតបនឹង IPV (បើអ្នកជំងឺមានអំពើហិង្សា)

# តើយើងអាចទាក់ទងដៃគូរបស់អ្នកតាមវិធីណា?



អ្នកនឹងប្រាប់ទៅ
ដៃគូដោយខ្លួនឯង




អ្នកនឹងប្រាប់ទៅដៃគូ
ក្នុងអំឡុងពេល៣០ថ្ងៃ



អ្នកផ្តល់សេវានឹងទាក់ទង
ទៅកាន់ដៃគូរបស់អ្នក




យើងនឹងសហការគ្នា
ប្រាប់ទៅដៃគូរបស់អ្នក

# ជំហានទី៥៖ ផ្តល់ជម្រើសនៃការជូនដំណឹងដៃគូទៅអ្នកជំងឺ




## សារគន្លឹះ៖

- មានវិធីផ្សេងៗគ្នាក្នុងការប្រាប់ដៃគូ សូមជ្រើសរើសជម្រើសដែលល្អបំផុតសម្រាប់អ្នក
- អ្នកអាចជូនដំណឹងដល់ពួកគេដោយខ្លួនឯង ឬខ្ញុំអាចជួយអ្នកបាន។
- យើងនឹងរក្សាភាពជាឯកជនរបស់ អ្នក

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- កុំសម្រេចថាការបញ្ជូនដោយអ្នកជំងឺជាជម្រើសតែមួយ ឬជម្រើសល្អបំផុត
- ព្យាយាមស្វែងយល់ពីការព្រួយបារម្ភរបស់គាត់ក្នុងការជូនដំណឹង និងបញ្ជូនដៃគូមកធ្វើតេស្ត
- អ្នកជំងឺអាចបញ្ជូនដៃគូដោយមិនបង្ហាញស្ថានភាពរបស់ពួកគាត់។ សួរបំផុសគំនិតជាមួយអ្នកជំងឺថាអាចធ្វើដូចនេះបានយ៉ាងដូចម្តេច
- កុំភ្លេចឆ្លុះបញ្ចាំងនូវភាសារបស់អ្នកជំងឺដែលគាំទ្រការបញ្ជូនដៃគូមកធ្វើតេស្ត

ក្នុងជម្រើសណាមួយក៏ដោយ ប្រសិនបើដៃគូរបស់អ្នកជំងឺមិនព្រម ឬមិនចង់ធ្វើតេស្តដោយអ្នកផ្តល់សេវា សូមផ្តល់ជម្រើសការធ្វើតេស្តដោយខ្លួនឯង

## ចំណុចពិភាក្សា

- ឥឡូវនេះ តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការណែនាំដៃគូមកធ្វើតេស្ត ?
  - ✓ តើអ្នកគិតថាយើងគួរជូនដំណឹងដល់ដៃគូរបស់អ្នកតាមវិធីណាដែរ ?
- ខ្ញុំមានបទពិសោធន៍មួយចំនួនទាក់ទងនឹងការជូនដំណឹងទៅដៃគូ។ បើខ្ញុំមានជម្រើសខ្លះសម្រាប់ចែករំលែកដល់អ្នក តើអ្នកយល់ព្រមដែរឬទេ ?
- យើងមានជម្រើសមួយចំនួនក្នុងការជូនដំណឹងដល់ដៃគូរបស់អ្នក។ វាអាស្រ័យទៅលើចំណង់ចំណូលចិត្តរបស់អ្នក៖
  - ✓ អ្នកលើកទឹកចិត្តដៃគូរបស់អ្នកឱ្យមកធ្វើតេស្តរកមេរោគអេដស៍។ ក្នុងកាលៈទេសៈនេះ អ្នកអាចចែករំលែក ឬជូនដំណឹងទៅដៃគូរបស់អ្នកដោយខ្លួនឯង
  - ✓ អ្នកផ្តល់ប្រឹក្សា ឬអ្នកផ្តល់សេវានឹងហៅទូរស័ព្ទ ឬក៏ជួបដៃគូអ្នក និងពន្យល់ប្រាប់ពួកគាត់ថាត្រូវទៅធ្វើតេស្តរកមេរោគអេដស៍។ បុគ្គលិកនឹងមិនប្រាប់ឈ្មោះរបស់អ្នកទៅដៃគូរបស់អ្នកទេ
  - ✓ អ្នក និងអ្នកផ្តល់ប្រឹក្សា នឹងធ្វើការជាមួយគ្នាក្នុងការជូនដំណឹងដល់ដៃគូរបស់អ្នក។ អ្នកមានរយៈពេល ៣០ថ្ងៃ ដើម្បីប្រាប់ទៅដៃគូ។ បន្ទាប់ពីនេះអ្នកផ្តល់ប្រឹក្សានឹងទាក់ទងទៅដៃគូរបស់អ្នក ប្រសិនបើមានការអនុញ្ញាតពីអ្នក
  - ✓ អ្នកផ្តល់ប្រឹក្សា នឹងជួបជាមួយអ្នក និងដៃគូរបស់អ្នក ហើយជួយគាំទ្រដល់ការពិភាក្សាអំពីការជូនដំណឹងនិងធ្វើតេស្ត។ ក្នុងកាលៈទេសៈនេះ អ្នកអាចចែករំលែក ឬមិនចែករំលែកពីស្ថានភាពមេរោគអេដស៍របស់អ្នក
- អ្នកមិនចាំបាច់ប្រាប់គ្រប់ដៃគូរបស់អ្នកដោយប្រើវិធីសាស្ត្រដូចគ្នានោះទេ។ អ្នកអាចជ្រើសរើសជម្រើសណាមួយដែលមានប្រសិទ្ធភាពជាមួយដៃគូណាមួយក៏បាន
- តើអ្នកគិតយ៉ាងណាដែរ ? ឬ អ្នកជ្រើសរើសយកការធ្វើតេស្តដោយខ្លួនឯងបានប្រសិនដៃគូរបស់អ្នកមិនចង់មកធ្វើតេស្តនៅទីនេះ

# តើអ្នកនឹងនិយាយជាមួយដៃគូរបស់អ្នកដោយវិធីណា?



- តោះធ្វើផែនការថាតើត្រូវនិយាយជាមួយដៃគូរបស់អ្នក៖
  - ពេលណា និងទីកន្លែងណាដែលអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព?
  - តើពួកគេនឹងមានប្រតិកម្មតបយ៉ាងដូចម្តេច?
  - តើសំណួរអ្វីខ្លះដែលពួកគេនឹងសួរ?
- ពិចារណាគួរមាននរណាម្នាក់នៅក្បែរ សម្រាប់ជួយគាំទ្រ ប្រសិនបើអ្នកត្រូវការ
- យើងអាចសាកល្បងអនុវត្តមុន រហូតដល់អ្នកមានទំនុកចិត្ត

# ជំហានទី៦៖ ធ្វើការជាមួយអ្នកជំងឺតម្រុយដើម្បីចាប់ផ្ដើមទាក់ទងដៃគូ និងកូនរបស់គាត់

## ជម្រើសទី១៖ ការបញ្ជូនដោយអ្នកជំងឺ




### សារគន្លឹះ

- ➢ ធ្វើផែនការថាតើអ្នកជំងឺ ត្រូវនិយាយទៅកាន់ដៃគូរបស់គាត់យ៉ាងដូចម្ដេច
- ➢ ពិចារណាថាតើដៃគូអាចមានប្រតិកម្មតបយ៉ាងដូចម្ដេច និងតើអ្នកជំងឺនឹងឆ្លើយតបយ៉ាងណាដែរ
- ➢ អនុវត្តនិយាយសាកល្បងរហូតអ្នកជំងឺមានទំនុកចិត្ត

### សេចក្ដីណែនាំសម្រាប់អ្នកផ្ដល់សេវា

- ប្រើសំណួរបើកដើម្បីស្វែងយល់ពីឧបសគ្គរបស់អ្នកជំងឺ៖ "តើអ្នកមានការលំបាកអ្វីខ្លះ?"
- ជួយអ្នកជំងឺក្នុងការជំនះឧបសគ្គទាំងនោះ "តើអ្នកដោះស្រាយបញ្ហានោះយ៉ាងដូចម្ដេច?" តើត្រូវការជំនួយអ្វីខ្លះ?
- ចងចាំថា ត្រូវឆ្លុះបញ្ចាំងត្រឡប់មកវិញពីមតិយោបល់ដែលជួយគាំទ្រដល់ការបញ្ជូនអ្នកជំងឺ
- កសាងទំនុកចិត្តរបស់អ្នកជំងឺតាមរយៈការអនុវត្តសាកល្បង

### កំណត់ត្រា

កត់ត្រាក្នុងផ្នែក "ផែនការជូនដំណឹង" នៃទម្រង់ ក២ ។ កត់ត្រារាល់ការព្យាយាមទាក់ទងក្នុងផ្នែក "ការព្យាយាមទាក់ទង" នៃទម្រង់ ក២

### ចំណុចពិភាក្សា

- ➢ មនុស្សជាច្រើនមានការភ័យខ្លាច ក្នុងការនិយាយទៅកាន់ដៃគូអំពីមេរោគអេដស៍ ប៉ុន្តែការយល់ព្រមក្នុងការជូនដំណឹងដល់ដៃគូនេះបង្ហាញថាអ្នកជាមនុស្សម្នាក់ ដែលចង់ជួយការពារពួកគេ។ ដូច្នេះ វាជាការល្អយើងគួររៀបចំផែនការមួយគ្នា
- ➢ នៅពេលអ្នកមានការលំបាកក្នុងការជជែកជាមួយដៃគូ ជាធម្មតា តើអ្នកដោះស្រាយយ៉ាងដូចម្ដេច?
- ➢ ពីកម្រិត១ ដល់១០ តើអ្នកមានទំនុកចិត្តប៉ុណ្ណា ក្នុងការជូនដំណឹងទៅដៃគូរបស់អ្នក? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វី ដែលធ្វើឱ្យអ្នកមានទំនុកចិត្តខ្ពស់បែបនេះ? (សូមប្រើការវាស់វែងអំពីការផ្លាស់ប្ដូរ ឬទំនុកចិត្តទំព័រទី៣៥)
- ➢ ខ្ញុំអាចចែករំលែកបទពិសោធន៍ខ្លះ ដែលអាចធ្វើឱ្យស្ថានភាពនេះប្រសើរជាងមុនបានទេ?
  - ✓ ជ្រើសរើសថ្ងៃ និងម៉ោងពេលដែលអ្នកមានពេលវេលាគ្រប់គ្រាន់ក្នុងការពិភាក្សា
  - ✓ ចៀសវាងពេលវេលាដែលដៃគូរបស់អ្នកខឹង ឬស្រវឹង
  - ✓ ជ្រើសរើសកន្លែងឯកជនមួយដែលអ្នកគិតថាមានផាសុកភាព
  - ✓ ពិចារណាថាតើអ្នកចង់មាននរណាម្នាក់នៅក្បែរ ដើម្បីជួយគាំទ្រដែរឬទេ
- ➢ តើអ្នកនឹងចាប់ផ្ដើមការពិភាក្សាយ៉ាងដូចម្ដេច?
- ➢ តើដៃគូរបស់អ្នកអាចមានប្រតិកម្មតបយ៉ាងដូចម្ដេច? តើអ្នកនឹងឆ្លើយតបយ៉ាងណាដែរ?
- ➢ ឱ្យក្រដាសបញ្ជូនទៅដៃគូរបស់អ្នក ដើម្បីគាត់កាន់យកមកជាមួយពេលទៅគ្លីនិក។ រំលឹកគាត់ថាការដឹងអំពីស្ថានភាពរបស់គាត់មានន័យថាគាត់អាចការពារខ្លួនគាត់។ ប្រសិនបើគាត់ទទួលលទ្ធផលវិជ្ជមាន គាត់អាចទៅទទួលការព្យាបាលដើម្បីជួយឱ្យគាត់រស់នៅបានយូរ និងមានសុខភាពល្អ។ ប្រសិនបើគាត់ទទួលលទ្ធផលអវិជ្ជមាន មានវិធីសាស្រ្តជាច្រើនដែលគាត់អាចអនុវត្តបាន ដើម្បីរក្សាស្ថានភាពអវិជ្ជមាននេះ។

# តើខ្ញុំអាចទាក់ទងទៅដៃគូរបស់អ្នក ដោយវិធីណា?



- យើងអាចជួយទាក់ទងដៃគូរបស់អ្នកបាន៖
  - យើងត្រូវការលេខទូរស័ព្ទ ឬបណ្តាញទំនាក់ទំនងផ្សេងៗ
  - បើអ្នកមាន យើងត្រូវការអាសយដ្ឋានបច្ចុប្បន្ន
- ដំបូងយើងនឹងហៅទូរស័ព្ទមុន ហើយបើសិនមិនដំណើរការ យើងនឹងព្យាយាមជួបផ្ទាល់នៅពេលបន្ទាប់
- យើងនឹងមិនប្រាប់ឈ្មោះ ឬព័ត៌មានណាមួយរបស់អ្នកទេ
- យើងនឹងក៏មិនប្រាប់អ្នកពីលទ្ធផលនៃការជូនដំណឹងនេះដែរ

# ជំហានទី៦៖ ធ្វើការជាមួយអ្នកជំងឺតម្រុយដើម្បីចាប់ផ្តើមទាក់ទងដៃគូ និងកូនរបស់គាត់

## ជម្រើសទី២៖ ការបញ្ជូនដោយអ្នកផ្តល់សេវា




### សារគន្លឹះ

- ធ្វើផែនការ ថាតើអ្នកផ្តល់សេវាត្រូវនិយាយទៅកាន់ដៃគូរបស់អ្នកយ៉ាងដូចម្តេច
- ពិចារណាថាតើពួកគាត់អាចមានប្រតិកម្មតបយ៉ាងដូចម្តេច និងថាតើអ្នកនឹងឆ្លើយតបយ៉ាងណាដែរ
- អនុវត្តសាកល្បងរហូតអ្នកមានទំនុកចិត្តក្នុងការនិយាយ

### សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- ចងចាំថា មិនត្រូវផ្តល់ព័ត៌មានដល់អ្នកដទៃក្រៅពីដៃគូដែលបានកំណត់រួចឡើយ
- ប្រើសន្លឹកខាងក្រោយនៃឧបសម្ព័ន្ធ២ដើម្បីជាជំនួយដល់ការហៅទូរស័ព្ទជូនដំណឹងទៅដៃគូ
- បើអ្នកមិនអាចទាក់ទងដៃគូតាមទូរស័ព្ទ មានចំនួន ៣ ដង សូមចុះទៅដល់អាសយដ្ឋានដៃគូនោះដោយប្រើសន្លឹកណែនាំដែលមាននៅឧបសម្ព័ន្ធ៣

### កំណត់ត្រា

កត់ត្រាចូលក្នុងផ្នែក "ផែនការជូនដំណឹង" នៃទម្រង់ ក២ ។ កត់ត្រារាល់ការព្យាយាមទាក់ទងក្នុងផ្នែក "ការព្យាយាមទាក់ទង" នៃទម្រង់ ក២.

### ចំណុចពិភាក្សា

➢ ខ្ញុំសូមកោតសរសើរអ្នកដែលចង់ការពារដៃគូរបស់អ្នក។ ប៉ុន្តែអ្នកមិនអាចនិយាយជាមួយពួកគាត់ដោយខ្លួនឯងបាន។ ការចែករំលែកផ្តល់ព័ត៌មានសម្រាប់ទំនាក់ទំនងដៃគូរបស់អ្នក មានន័យថាអ្នកកំពុងជួយខ្ញុំឱ្យជួយពួកគាត់បាន

➢ តើជាធម្មតាអ្នកទាក់ទងដៃគូរបស់អ្នកដោយរបៀបណា? តើមានវិធីល្អបំផុតណាខ្លះដើម្បីទាក់ទងទៅគាត់?

- ✓ លេខទូរស័ព្ទ?
- ✓ អ៊ីម៉ែល ឬបណ្តាញសង្គម?
- ✓ អាសយដ្ឋានបច្ចុប្បន្ន?

➢ ដំបូងយើងនឹងព្យាយាមហៅទូរស័ព្ទ ឬផ្ញើសារទៅគាត់សិន។ បើសិនជាមិនអាចទាក់ទងបានទេ យើងនឹងមានបុគ្គលិកផ្សេងទៀតទៅជួបគាត់ដល់ផ្ទះ

➢ ទោះយ៉ាងណាក៏ដោយ យើងនឹងមិនប្រាប់ឈ្មោះអ្នកឬព័ត៌មានរបស់អ្នកដល់គាត់ទេ

➢ ដើម្បីរក្សាការសម្ងាត់ យើងក៏នឹងមិនប្រាប់អ្នកថាដៃគូរបស់អ្នកបានធ្វើតេស្ត ឬអត់ ឬក៏បានទទួលលទ្ធផលតេស្តយ៉ាងណានោះដែរ

# តើអ្នកនឹងប្រាប់នៅដៃគូក្នុងអំឡុងពេល៣០ថ្ងៃ ដោយវិធីណា?

- តោះធ្វើផែនការ ថាតើត្រូវនិយាយជាមួយដៃគូរបស់អ្នក៖
  - ពេលណា និងទីកន្លែងណាដែលអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព?
  - តើពួកគេនឹងមានប្រតិកម្មតបយ៉ាងដូចម្តេច?
  - តើសំណួរអ្វីខ្លះដែលពួកគេនឹងសួរ?
- ពិចារណាគួរមានអ្នកណានៅក្បែរសម្រាប់ជួយគាំទ្រ ប្រសិនបើអ្នកត្រូវការ
- យើងអាចអនុវត្តសាកល្បង រហូតដល់អ្នកមានទំនុកចិត្ត
- បើអ្នកបរាជ័យក្នុងការទាក់ទងទៅដៃគូនេះ យើងអាចតាមដានជាមួយគាត់បន្តបាន



# ជំហានទី៦៖ ធ្វើការជាមួយអ្នកជំងឺតម្រុយដើម្បីចាប់ផ្តើមទាក់ទងដៃគូ និងកូនរបស់គាត់

## ជម្រើសទី៣៖ ការបញ្ជូនដោយមានកិច្ចព្រមព្រៀង



### សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- ប្រើសំណួរបើកដើម្បីស្វែងយល់ ពីឧបសគ្គរបស់អ្នកជំងឺ៖ "តើអ្នកមានការលំបាកអ្វីខ្លះក្នុងការជូនដំណឹងទៅដៃគូ?"
- ជួយអ្នកជំងឺក្នុងការជំនះឧបសគ្គទាំងនោះ៖ "តើអ្នកដោះស្រាយបញ្ហានោះយ៉ាងដូចម្តេច?" "តើអ្នកត្រូវការជំនួយអ្វីខ្លះ?"
- កសាងទំនុកចិត្តរបស់អ្នកជំងឺ តាមរយៈការសាកល្បងអនុវត្តជាមួយគាត់
- តាមដានបន្ត៖ បើអ្នកជំងឺបរាជ័យ ក្នុងការទាក់ទងជាមួយដៃគូរបស់គាត់បន្ទាប់ពីរយៈពេលមួយខែ សុំអនុញ្ញាតពីអ្នកជំងឺក្នុងការទាក់ទងដៃគូគាត់ផ្ទាល់។ ប្រើឧបសម្ព័ន្ធខាងក្រោយសម្រាប់ធ្វើ កិច្ចការនេះ

### តោះរំលឹកឡើងវិញ

- តើពេលវេលាណា និងទីកន្លែងដែលល្អ ដើម្បីជជែកជាមួយដៃគូរបស់អ្នក?
- តើអ្នកចាប់ផ្តើមការពិភាក្សាយ៉ាងដូចម្តេច?
- តើអ្នកអាចពន្យល់ពីសារប្រយោជន៍ នៃការធ្វើតេស្តដល់ដៃគូរបស់អ្នកបានដែរឬទេ?
  តើអ្នកនឹងព្យាយាមទាក់ទងទៅដៃគូនេះនៅពេលណា?

### កំណត់ត្រា

កត់ត្រាចូលទៅផ្នែក "ផែនការជូនដំណឹង" នៃទម្រង់ ក២ នូវកាលបរិច្ឆេទដែលអតិថិជនចាប់ផ្តើមទាក់ទងទៅដៃគូរបស់គាត់។ បើអ្នកជំងឺមិនអនុញ្ញាតឱ្យទាក់ទងដៃគូទេ កត់ត្រាលទ្ធផលនេះ ក្នុងផ្នែក "លទ្ធផល" ចំពោះដៃគូនេះក្នុងទម្រង់ ក២

### ចំណុចពិភាក្សា

- ➢ មនុស្សជាច្រើនមានការភ័យខ្លាច ក្នុងការនិយាយទៅកាន់ដៃគូរបស់ពួកគេ អំពីមេរោគអេដស៍។ ដូច្នេះ វាជាការល្អយើងគួររៀបចំផែនការមួយ។ តើអ្នកគិតយ៉ាងណានៅពេលអ្នកមានការលំបាកក្នុងការជជែកគ្នាជាមួយដៃគូ?
- ➢ ពីកម្រិត១ ដល់១០ តើអ្នកមានទំនុកចិត្តប៉ុណ្ណា ក្នុងការជូនដំណឹងទៅដៃគូរបស់អ្នក? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វីដែលធ្វើឱ្យអ្នកមានទំនុកចិត្តខ្ពស់បែបនេះ? (សូមប្រើការវាស់វែងអំពីការផ្លាស់ប្តូរ ឬទំនុកចិត្តទំព័រទី៣៥)
- ➢ តើខ្ញុំអាចចែករំលែកបទពិសោធន៍ខ្លះ ដែលអាចធ្វើឱ្យស្ថានភាពនេះប្រសើរជាងមុនបានទេ?
  - ✓ ជ្រើសរើសថ្ងៃ និងម៉ោងពេលដែលអ្នកមានពេលវេលាគ្រប់គ្រាន់ ក្នុងការពិភាក្សា
  - ✓ ចៀសវាងពេលវេលា ដែលដៃគូរបស់អ្នកខឹង ឬស្រវឹង
  - ✓ ជ្រើសរើសកន្លែងឯកជន ដែលអ្នកគិតថាមានផាសុកភាព
  - ✓ ពិចារណាថាតើអ្នកចង់មាននរណាម្នាក់នៅក្បែរដើម្បីជួយគាំទ្រដែរឬទេ
- ➢ តើអ្នកនឹងចាប់ផ្តើមការពិភាក្សាយ៉ាងដូចម្តេច?
- ➢ តើដៃគូរបស់អ្នកអាចមានប្រតិកម្មតបយ៉ាងដូចម្តេច?
- ➢ តើអ្នកនឹងពន្យល់អំពីសារៈសំខាន់នៃការធ្វើតេស្ត ដោយវិធីណា?
- ➢ តោះកំណត់កាលបរិច្ឆេទ ដើម្បីយើងទាក់ទងគាត់តាមទូរស័ព្ទ។ បើអ្នកមិនអាចទាក់ទងបានទេ ខ្ញុំអាចព្យាយាមទាក់ទងគាត់ផ្ទាល់ ប្រសិនបើអ្នកអនុញ្ញាត។
  - ✓ តើអ្នកគិតថាត្រូវចំណាយពេលប៉ុន្មាន ក្នុងការទាក់ទងគាត់បាន?

# តើយើងសហការគ្នា ប្រាប់ទៅដៃគូរបស់អ្នកដោយវិធីណា ?

- ការនិយាយពីមេរោគអេដស៍ ជាការលំបាក ប៉ុន្តែអ្នកមិនឯកោទេ យើងអាចធ្វើការងារនេះទាំងអស់គ្នា
- តោះយើងធ្វើផែនការដើម្បីនិយាយជាមួយដៃគូរបស់អ្នក៖
  - តើធ្វើនៅពេលណា និងទីកន្លែងណា ?
  - តើមានចំណុចអ្វីដែលខ្ញុំគួរនិយាយ ?
  - តើមានចំណុចអ្វីខ្លះដែលខ្ញុំមិនគួរនិយាយ ?
- តើយើងអាចដោះស្រាយបញ្ហាប្រឈមនេះយ៉ាងដូចម្តេច ?



# ជំហានទី៦៖ ធ្វើការជាមួយអ្នកជំងឺតម្រុយដើម្បីចាប់ផ្តើមទាក់ទងដៃគូ និងកូនរបស់គាត់

## ជម្រើសទី៤៖ ការបញ្ជូនដោយអ្នកជំងឺ និងអ្នកផ្តល់សេវា




### សារគន្លឹះ

- ➢ យើងអាចទាក់ទងដៃគូរបស់អ្នកទាំងអស់គ្នា
- ➢ គិតថាតើអ្វីដែលអ្នកចង់ឱ្យខ្ញុំនិយាយ (និងអ្វីដែលខ្ញុំមិនគួរនិយាយ)
- ➢ ពិចារណាថាតើគាត់អាចមានប្រតិកម្មតបយ៉ាងដូចម្តេច និងតើយើងនឹងឆ្លើយតបយ៉ាងណាដែរ

### សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- ចងចាំថាអ្នកជំងឺរបស់អ្នកដឹងអំពីដៃគូរបស់គាត់ច្រើនជាងអ្នក។ សុំយោបល់គាត់តើគួរធ្វើការពិភាក្សាយ៉ាងណា
- កំណត់កាលបរិច្ឆេទដើម្បីជួបដដែកគ្នា
- បើការជជែកគ្នាធ្វើឡើងនៅមណ្ឌលសុខភាព ជូនលិខិតអញ្ជើញដល់គាត់ដើម្បីគាត់យកទៅឱ្យដៃគូ

### កំណត់ត្រា

កត់ត្រាកាលបរិច្ឆេទចំពោះការបញ្ជូនដោយអ្នកជំងឺ និងអ្នកផ្តល់សេវាក្នុងផ្នែក "ផែនការជូនដំណឹង" នៃទម្រង់ ក២៕ កត់ត្រារាល់ការព្យាយាមទាក់ទងក្នុងផ្នែក "ការព្យាយាមទាក់ទង" នៃទម្រង់ ក២

### ចំណុចពិភាក្សា

- ➢ និយាយជាមួយដៃគូពីប្រធានបទរសើបមួយពិតជាលំបាក ប៉ុន្តែអ្នកមិននិយាយគ្នាតែម្នាក់ឯងទេ។ ខ្ញុំអាចជួយអ្នកក្នុងការពិភាក្សានេះ ប៉ុន្តែយើងត្រូវធ្វើផែនការមួយអំពីវិធីសាស្ត្រសម្រាប់ការពិភាក្សានេះ
- ➢ តើនៅទីណា ដែលអ្នកមានទំនុកចិត្តក្នុងការនិយាយ?
- ➢ តើពេលវេលាណា ដែលល្អបំផុតដើម្បីនិយាយគ្នា?
- ➢ ដើម្បីឱ្យខ្ញុំជួយអ្នកបានពេញលេញ ខ្ញុំត្រូវការព័ត៌មានខ្លះ៖
  - ✓ តើអ្នកចង់ឱ្យខ្ញុំនិយាយអ្វីខ្លះទៅដៃគូរបស់អ្នក?
  - ✓ តើមានអ្វីខ្លះដែលអ្នកមិនចង់ឱ្យខ្ញុំនិយាយ?
- ➢ តើអ្នកមើលឃើញបញ្ហាប្រឈមអ្វីខ្លះ ដែលយើងអាចជួបប្រទះនៅពេលនិយាយជាមួយដៃគូរបស់អ្នក?
  - ✓ តើអ្នកគិតថាគាត់អាចមានប្រតិកម្មតបយ៉ាងដូចម្តេច? តើគាត់អាចសួរសំណួរអ្វីខ្លះ?
- ➢ តើអ្នកគិតថាយើងអាចជំនះបញ្ហាប្រឈមទាំងនេះ ដោយរបៀបណា?
  - ✓ នៅពេលអ្នកធ្លាប់មានបញ្ហាទាំងនេះកន្លងមកជាមួយដៃគូ តើអ្នកដោះស្រាយយ៉ាងណា?

# សូមអរគុណ

## ខ្ញុំសង្ឃឹមថានឹងជួបអ្នកម្តងទៀត!





# បញ្ចប់វគ្គនៃការប្រឹក្សា លើសេវាតាមរកដៃគូ




## សារគន្លឹះ

- តាមរយៈការជូនដំណឹងដល់ដៃគូ គឺអ្នកកំពុងជួយមនុស្សជាទីស្រឡាញ់របស់អ្នក
- សង្ខេបពីមូលហេតុ និងមានផែនការអ្វីខ្លះ ដែលបានព្រមព្រៀងដើម្បីជំនះឧបសគ្គទាំងនោះ
- យើងអាចធ្វើការជាមួយគ្នាលើបញ្ហាផ្សេងទៀត ដែលកើតមានឡើង

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- ការយល់ព្រមទទួលសេវាតាមរកដៃគូ មិនមានន័យថាអ្នកជំងឺអ្នកនឹងធ្វើតាមអ្នកទាំងស្រុងទេ។ លើកទឹកចិត្តពួកគេតាមរយៈការឆ្លុះបញ្ចាំងពីមូលហេតុដែលគាត់មានក្នុងការជូនដំណឹងដល់ដៃគូ និងផែនការដើម្បីជំនះឧបសគ្គរបស់គាត់។
- អ្នកជំងឺអាចមានបញ្ហាជាអាទិភាពផ្សេងៗទៀត។ កុំភ្លេចពិនិត្យថាតើអ្នកអាចផ្តល់ការគាំទ្រអ្វីខ្លះទៀតដល់គាត់បាន

## កំណត់ត្រា

កត់ត្រាកាលបរិច្ឆេទសម្រាប់ការជួបជាមួយអ្នកជំងឺនៅពេលបន្ទាប់ក្នុងទម្រង់ ក២។ កុំភ្លេចកត់ត្រាបន្ថែមនូវអ្វីដែលអ្នកត្រូវការសម្រាប់ត្រៀមនៅពេលជួបគាត់ពេលក្រោយ

## ចំណុចពិភាក្សា

- សូមអរគុណសម្រាប់ការចំណាយពេលវេលានិយាយជាមួយខ្ញុំនៅថ្ងៃនេះ អំពីវិធីបញ្ជូនដៃគូរបស់អ្នកមកធ្វើតេស្ត។ ខ្ញុំដឹងថាវាជាប្រធានបទដែលពិបាក ប៉ុន្តែអ្នកបង្ហាញថាអ្នកជាមនុស្សដែលបារម្ភពីអ្នកដទៃ ថ្វីត្បិតតែវាមិនមែនជារឿងងាយស្រួលក៏ដោយ!
- សង្ខេបខ្លីមកវិញពីការពិភាក្សាជាមួយអ្នកជំងឺរបស់អ្នក៖
  - អ្នកបាននិយាយថា៖ [សង្ខេបមូលហេតុសំខាន់ៗដែលគាត់ចង់ជូនដំណឹងដល់ដៃគូ]
  - អ្នកបង្ហាញពីក្តីបារម្ភមួយចំនួន៖ [សង្ខេបខ្លីពីកង្វល់របស់អ្នកជំងឺ]
  - យើងបានព្រមព្រៀងគ្នា ដើម្បីជំនះឧបសគ្គ អ្នក/យើងនឹង៖ [សង្ខេបផែនការសំខាន់ៗ]
- ត្រឹមត្រូវទេ? តើអ្នកមានអ្វីផ្សេងទៀតដែលខ្ញុំអាចជួយបានទេក្នុងថ្ងៃនេះ?
- បន្ទាប់ពីការពិភាក្សាចំណុចទាំងអស់នេះ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ?
- ខ្ញុំចង់និយាយជាមួយអ្នកម្តងទៀត ដើម្បីសួរសុខទុក្ខថាអ្នកសុខសប្បាយទេ និងតើការបញ្ជូនដៃគូអ្នកដល់ណាហើយ។ តើពេលវេលាណាល្អដែលយើងអាចជួបគ្នាទៀត?

# តើអ្នកមានការតាំងចិត្ត ឬជឿជាក់កម្រិតណា ក្នុងការនិយាយជាមួយដៃគូរបស់អ្នក?



# ការវាស់វែងពីការតាំងចិត្ត និងភាពជឿជាក់ក្នុងការជូនដំណឹង




## សារគន្លឹះ

- ❖ ប្រើការវាស់វែងពីការតាំងចិត្ត ឬភាពជឿជាក់ក្នុងការជួយអ្នកជំងឺជូនដំណឹងដៃគូ
- ❖ លើកទឹកចិត្តអ្នកជំងឺពីការតាំងចិត្ត និងគាំទ្រចំពោះការផ្លាស់ប្តូរ

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- ការជូនដំណឹងដៃគូពឹងផ្អែកលើភាពក្លាហានរបស់អ្នកជំងឺ
- ប្រើរូបភាពបន្ទាត់សម្រាប់ការវាស់វែងការតាំងចិត្ត ឬភាពជឿជាក់របស់អ្នកជំងឺ
- ប្រើសំណួរបើក ដើម្បីដឹងពីហេតុផលពីការតាំងចិត្តដូច្នេះ
- បង្កើនការលើកទឹកចិត្ត និងកសាងទំនុកចិត្តរបស់អ្នកជំងឺតាម រយៈការឆ្លុះបញ្ចាំងត្រឡប់មកវិញនូវមូលហេតុដែលគាត់អាចធ្វើបាន

## ចំណុចពិភាក្សា

ការតាំងចិត្តវាបង្ហាញពីការផ្លាស់ប្តូររបស់អ្នក ក្នុងការជូនដំណឹងទៅដៃគូពីការធ្វើតេស្តរកមេរោគអេដស៍។ វិធីខាងក្រោមអាចជួយអ្នកក្នុងការវាស់វែងពីការតាំងចិត្តនោះបាន។

- ➤ អ្នកថានឹងយករឿងនេះទៅនិយាយជាមួយដៃគូរបស់អ្នក។ បើសិនឱ្យអ្នករើសពីលេខ១ ដល់លេខ១០ (លេខ១មានន័យថាការជឿជាក់ទាបបំផុត ហើយលេខ១០ មានការជឿជាក់ខ្ពស់បំផុត) តើអ្នកជ្រើសរើសយកលេខប៉ុន្មាន? *(សូមប្រើការវាស់វែងអំពីការផ្លាស់ប្តូរ ឬទំនុកចិត្តទំព័រ-៣៥)*
- ➤ ខ្ញុំយកលេខ______
- ➤ ប្រសើរណាស់ដែលប្អូនរើសយកលេខ____ ជាជាងយកត្រឹមលេខ____ តើប្អូនអាចប្រាប់ហេតុផលសំខាន់ៗបានទេ?
- ➤ ខ្ញុំរើសយកលេខ__ មិនយកត្រឹម___ទេព្រោះខ្ញុំ________________
- ➤ នេះជាការសម្រេចចិត្តរបស់អ្នក ខ្ញុំសង្ឃឹមថាអ្នកនឹងធ្វើបាន។ ជូនពរឱ្យអ្នកសម្រេចបានតាមគោលបំណងដែលអ្នកចង់បាន

# យើងជួយក្នុងការការពារសុខភាពរបស់អ្នក...



- អ្នកអាចប្រឈមនឹងការឆ្លងមេរោគអេដស៍
- ការព្យាបាលទាន់ពេលវេលា អ្នករស់នៅជាមួយមេរោគអេដស៍អាចៈ
  - រស់នៅបានយូរអង្វែង និងមានសុខភាពល្អ
  - កាត់បន្ថយការចម្លងមេរោគអេដស៍ទៅអ្នកដទៃ
- បើអ្នកអវិជ្ជមាននៃមេរោគអេដស៍ អ្នកមានជម្រើសជាច្រើនក្នុងការធានាថាអ្នកនៅតែអវិជ្ជមានរហូត

# ជួបជាមួយដៃគូផ្ទាល់ (យើងជួយការពារសុខភាពរបស់អ្នក...)




## សារគន្លឹះ

❖ ការធ្វើតេស្ត ជាវិធីតែមួយគត់ដើម្បីដឹងពីស្ថានភាពមេរោគអេដស៍របស់អ្នក

❖ បើមិនបានធ្វើតេស្តទេ អ្នកមិនអាចការពារខ្លួនអ្នកបានឡើយ

❖ យើងផ្តល់ជម្រើសផ្សេងៗដើម្បីឱ្យអ្នកដឹងពីស្ថានភាពមេរោគអេដស៍របស់អ្នក

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- មិនត្រូវផ្តល់ព័ត៌មានទៅអ្នកដទៃក្រៅពីដៃគូ
- បើដៃគូសួរថាអ្នកណាផ្តល់ព័ត៌មាននេះ ត្រូវនិយាយថា "ជាការសម្ងាត់ ខ្ញុំមិនអាចប្រាប់បានទេ បើអ្នកយល់ព្រមធ្វើតេស្ត យើងក៏នឹងមិនចែករំលែកព័ត៌មានរបស់អ្នកដូចគ្នា"
- បង្កើនការលើកទឹកចិត្ត និងកសាងទំនុកចិត្តរបស់ដៃគូតាមរយៈការឆ្លុះបញ្ចាំងត្រឡប់មកវិញនូវមូលហេតុដែលគាត់គួរធ្វើតេស្ត
- កុំព្យាយាមបង្ខំដៃគូដែលមិនចង់ធ្វើតេស្ត។ ទុកឱកាសសម្រាប់ពិភាក្សា ពីការទទួលធ្វើតេស្តពេលក្រោយ

## កំណត់ត្រា

កត់ត្រាលទ្ធផលនៃការព្យាយាមទាក់ទងជាមួយដៃគូក្នុងផ្នែក "ព្យាយាមទាក់ទង" នៃទម្រង់ ក២។ កត់ត្រាកាលបរិច្ឆេទ/អាសយដ្ឋានដៃគូធ្វើតេស្ត

## ចំណុចពិភាក្សា

➢ ពីកម្រិត១ ដល់១០ តើអ្នកមានទំនុកចិត្តប៉ុណ្ណាក្នុងការដឹងពីស្ថានភាពជំងឺអេដស៍របស់អ្នក? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វី ដែលធ្វើឱ្យអ្នកមានទំនុកចិត្តខ្ពស់បែបនេះ?

➢ ពីកម្រិត ១ ដល់ ១០ តើអ្នកមានទំនុកចិត្តយ៉ាងណាដែលអំពីការទៅធ្វើតេស្តបើអ្នកចង់? ហេតុអ្វីបានជាមិនជ្រើសយកទាបជាងនេះ? តើមានហេតុផលអ្វីដែលធ្វើឱ្យអ្នកមានទំនុកចិត្តខ្ពស់បែបនេះ? (សូមប្រើការវាស់វែងអំពីការផ្លាស់ប្តូរ ឬទំនុកចិត្តទំព័រទី៣៥)

➢ អ្វីដែលខ្ញុំបានឮគឺថាអ្នក [សង្ខេបមូលហេតុនៃការធ្វើតេស្តរបស់អតិថិជន]។ តើអ្នកគិតថាអ្នកត្រៀមរួចរាល់ហើយឬនៅក្នុងការដឹងពីស្ថានភាពរបស់អ្នក?

➢ [បើ "បាទ/ចាស"] កន្លែងយើងខ្ញុំ មានផ្តល់សេវាធ្វើតេស្ត [ម៉ោងធ្វើការ]។ យើងក៏អាចបញ្ជូនអ្នកផ្តល់ប្រឹក្សាទៅជួបអ្នកនៅផ្ទះ ឬនៅកន្លែងផ្សេងទៀតសម្រាប់ធ្វើតេស្ត ឬអ្នកអាចយកតេស្តទៅធ្វើដោយខ្លួនឯងបាន។ តើអ្នកពេញចិត្តជម្រើសមួយណា?

➢ [បើ "ទេ"] តើអ្នកមានកង្វល់អ្វីខ្លះចំពោះការធ្វើតេស្ត?
  – បើអ្នកមិនដឹងពីស្ថានភាពរបស់អ្នកទេ តើអ្នកគិតថាលទ្ធផលអាក្រក់បំផុតអាចជាអ្វី?
  – តើមានចំណុចល្អអ្វីខ្លះបើអ្នកដឹងពីស្ថានភាពរបស់អ្នក?

➢ [បើដៃគូនៅតែមិនព្រម] នេះជាព័ត៌មានសម្រាប់ទាក់ទងរបស់ខ្ញុំ។ អ្នកអាចទាក់ទងមកខ្ញុំពេលណាក៏បាន ប្រសិនបើអ្នកប្តូរចិត្ត ឬមានចម្ងល់ផ្សេងៗដែលអ្នកចង់ពិភាក្សា

# ឧបសម្ព័ន្ធទី១៖ រំឭកអំពីជំហានសំខាន់ៗ ដើម្បីប៉ាន់ប្រមាណ និងឆ្លើយតបនឹង IPV

## ជំហានសំខាន់ៗដើម្បីធ្វើការប៉ាន់ប្រមាណអំពីហានិភ័យ IPV

អ្នកជំងឺធ្វើតេស្តមានមេរោគអេដស៍+ (អ្នកជំងឺតម្រុយថ្មី)

↓

សេវាតាមរកដៃគូ ត្រូវបានផ្ដល់ជូន និងទទួលយក

→

**1** អ្នកផ្ដល់សេវាប៉ាន់ប្រមាណអំពីហានិភ័យIPVដោយសួរសំណួរស្តង់ដារទាក់ទងនឹង IPV សម្រាប់ដៃគូនីមួយៗ

**មិនមាន** → អំពើហិង្សាមិនត្រូវបានលាតត្រដាង ឬ សង្ស័យ → ផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយអំពីសេវាGBVផ្សេងៗដែលអាចរកបាន → រៀបផែនការតាមរកដៃគូ → តាមដានអ្នកជំងឺអំពីព្រឹត្តិការណ៍អវិជ្ជមានណាមួយបន្ទាប់ពីការធ្វើតេស្តដៃគូ

**មាន** → អំពើហិង្សាត្រូវបានលាតត្រដាង ឬ សង្ស័យ →

**2** **គ្រប់អ្នកជំងឺដែលបានប្រាប់ពីករណី IPV ត្រូវតែផ្ដល់ការ**គាំទ្រដំបូង (LIVES): ការស្តាប់ ការសាកសួរអំពីកង្វល់ និងតម្រូវការផ្សេងៗ ការបញ្ជាក់ពីភាពត្រឹមត្រូវការពង្រឹងសុវត្ថិភាព និងការគាំទ្រ

↓

1. **ផ្ដល់ព័ត៌មាន**គ្រប់ជ្រុងជ្រោយ អំពីសេវា GBV ផ្សេងៗ ដែលអាចរកបាន
2. **បញ្ជូន** អ្នកជំងឺ ទៅទទួលសេវា GBV សមស្រប តាមតែអាចធ្វើទៅបាន (ប្រសិនបើមានការយល់ព្រម/ ការស្នើសុំពីអតិថិជន)

↓

**3** អ្នកផ្ដល់សេវាណែនាំឱ្យពួកគេមិនជូនដំណឹងដល់ដៃគូ។ **ប្រសិនបើអ្នកជំងឺ ស្នើសុំការជូនដំណឹងដល់ដៃគូជាពិសេស តើអ្នកជំងឺនឹងមានសុវត្ថិភាពដែរឬទេ?**

**សុវត្ថិភាព** → បន្តដោយធ្វើសកម្មភាពការជូនដំណឹងដល់ដៃគូ។ ពិចារណាវិធីសាស្ត្រដែលមិនតម្រូវឱ្យមានការបញ្ចេញអត្តសញ្ញាណអ្នកជំងឺ

**មិនសុវត្ថិភាព** → កុំបន្តទៅមុខដោយមានការជូនដំណឹងដល់ដៃគូ

# ឧបសម្ព័ន្ធទី២៖ ការទាក់ទងជាមួយដៃគូតាមរយៈទូរស័ព្ទ

## សារគន្លឹះ

- ❖ អ្នកអាចប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ហើយអ្នកត្រូវធ្វើតេស្ត ដើម្បីបញ្ជាក់ពីស្ថានភាពសុខភាពរបស់អ្នក
- ❖ បើលទ្ធផលវិជ្ជមាន អ្នកនឹងទទួលការព្យាបាល ដើម្បីជួយឱ្យរស់នៅបានយូរ។ បើលទ្ធផលអវិជ្ជមាន យើងអាចជួយអ្នកឱ្យរក្សាស្ថានភាពអវិជ្ជមាននេះ
- ❖ យើងមានជម្រើសផ្សេងៗក្នុងការយល់ដឹងស្ថានភាពមេរោគអេដស៍របស់អ្នក

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- មិនត្រូវផ្តល់ព័ត៌មានទៅអ្នកដទៃក្រៅពីដៃគូ
- បើដៃគូសួរថាអ្នកណាផ្តល់ព័ត៌មាននេះ ត្រូវនិយាយថា "ជាការណ៍សម្ងាត់ ខ្ញុំមិនអាចប្រាប់បានទេ ។ បើអ្នកយល់ព្រមធ្វើតេស្ត យើងក៏មិនចែករំលែកព័ត៌មានរបស់អ្នកដូចគ្នា"
- បើមិនអាចទាក់ទងតាមទូរស័ព្ទ ក្នុងរយៈពេល៣ដង ចូរអ្នកចុះទៅដល់ផ្ទះដៃគូ តាមរយៈអាសយដ្ឋានដែលមាន។ សូមប្រើឧបសម្ព័ន្ធខាងក្រោយជាជំនួយ
- ប្រសិនបើដៃគូមិនព្រម ឬមិនចង់ទៅធ្វើតេស្ត សូមផ្តល់ជម្រើសការធ្វើតេស្តដោយខ្លួនឯង

## កំណត់ត្រា

កត់ត្រាលទ្ធផល នៃការព្យាយាមទាក់ទងជាមួយដៃគូនៅផ្នែក "ព្យាយាមទាក់ទង" នៃទម្រង់ ក២។ កត់ត្រាកាលបរិច្ឆេទ/អាសយដ្ឋានដៃគូ ឬលទ្ធផលធ្វើតេស្តប្រសិនបានធ្វើតេស្ត

## ចំណុចពិភាក្សា

- ➢ ជម្រាបសួរ ខ្ញុំឈ្មោះ ______________។ ខ្ញុំកំពុងនិយាយ [ឈ្មោះអ្នកទាក់ទង] មែនទេ?
  - ✓ បើ "ទេ"៖ [ឈ្មោះអ្នកទាក់ទង] តើពេលណាគាត់ត្រឡប់មកវិញ?
  - ✓ បើមិនទំនេរទេ៖ អរគុណ – ខ្ញុំនឹងទាក់ទងមកអ្នកម្តងទៀត។
- ➢ បើទំនេរអាចនិយាយបាន៖ ខ្ញុំជាអ្នកផ្តល់ប្រឹក្សា/បុគ្គលិកសុខាភិបាលនៅ [ឈ្មោះទីកន្លែងធ្វើការ]។ តើអ្នកពេលនេះជាឱកាសល្អសម្រាប់និយាយពិភាក្សាទេ?
  - ✓ បើ "ទេ"៖ តើពេលណាខ្ញុំអាចហៅទូរស័ព្ទមកអ្នកម្តងទៀតបាន?
- ➢ បើគាត់ព្រម៖ យើងបានដឹងថា អ្នកធ្លាប់បានប្រឈមនឹងការឆ្លងមេរោគអេដស៍។ តើអ្នកយល់យ៉ាងណាដែរ?
  - ✓ បើអ្នកមិនមានមេរោគអេដស៍ យើងអាចជួយអ្នកឱ្យនៅតែអវិជ្ជមាន។
  - ✓ បើអ្នកមានមេរោគអេដស៍ អ្នកអាចទទួលការព្យាបាល ដោយថ្នាំប្រឆាំងមេរោគអេដស៍ ដើម្បីជួយអ្នកឱ្យរស់នៅបានយូរ និងមានសុខភាពល្អ។ ការព្យាបាលក៏អាចជួយកាត់បន្ថយការចម្លងមេរោគអេដស៍របស់អ្នកទៅអ្នកដែលខ្លួនស្រឡាញ់បានដែរ។
- ➢ បន្ទាប់ពីដឹងព័ត៌មាននេះ តើអ្នកមានអារម្មណ៍យ៉ាងណាអំពីការមកធ្វើតេស្ត?
- ➢ វាមានសារសំខាន់ណាស់ ដែលអ្នកមកធ្វើតេស្តរកមេរោគអេដស៍។ នៅកន្លែងយើងខ្ញុំមានសេវាធ្វើតេស្ត [ម៉ោងធ្វើការ]។ យើងអាចបញ្ជូនអ្នកផ្តល់ប្រឹក្សាទៅជួបអ្នកនៅផ្ទះ ឬនៅកន្លែងណាមួយសម្រាប់ធ្វើតេស្តបាន។ តើអ្នកពេញចិត្តជម្រើសណាមួយដែរ ?

# ឧបសម្ព័ន្ធទី៣៖ ការទាក់ទងជាមួយដៃគូដោយផ្ទាល់

## សារគន្លឹះ

- អ្នកអាចប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ហើយអ្នកត្រូវធ្វើតេស្ត ដើម្បីបញ្ជាក់ពីស្ថានភាពសុខភាពរបស់អ្នក
- បើលទ្ធផលវិជ្ជមាន អ្នកនឹងទទួលការព្យាបាល ដើម្បីជួយឱ្យរស់នៅបានយូរ។ បើលទ្ធផលអវិជ្ជមាន យើងអាចជួយអ្នកឱ្យរក្សាស្ថានភាពអវិជ្ជមាននេះ
- យើងមានជម្រើសផ្សេងៗ ក្នុងការយល់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់អ្នក

## សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវា

- មិនត្រូវផ្តល់ព័ត៌មានទៅអ្នកដទៃក្រៅពីដៃគូ
- បើដៃគូសួរថាអ្នកណាផ្តល់ព័ត៌មាននេះ ត្រូវនិយាយថា "ជាការសម្ងាត់ ខ្ញុំមិនអាចប្រាប់បានទេ ។ បើអ្នកយល់ព្រមធ្វើតេស្ត យើងក៏នឹងមិនចែករំលែកព័ត៌មានរបស់អ្នកដូចគ្នាដែរ"
- បើមិនអាចទាក់ទងតាមទូរស័ព្ទ ក្នុងរយៈពេល៣ដង ចូរអ្នកចុះទៅដល់ផ្ទះដៃគូតាមរយៈអាសយដ្ឋានដែលមាន។ ប្រើសន្លឹក៣៧-៣៨ជាជំនួយ

ក្នុងជម្រើសណាមួយក៏ដោយ ប្រសិនបើដៃគូរបស់អ្នកជំងឺមិនព្រម ឬមិនចង់ធ្វើតេស្ត ដោយអ្នកផ្តល់សេវា សូមផ្តល់ជម្រើសការធ្វើតេស្តដោយខ្លួនឯង

## ចំណុចពិភាក្សា

- ជម្រាបសួរ ខ្ញុំឈ្មោះ ______________ ។ ខ្ញុំចង់ជួបរក [ឈ្មោះអ្នកទាក់ទង] ។ តើគាត់នៅដែរឬទេ?
  - ✓ បើ "ទេ"៖ អរគុណ តើដឹងថាពេលណាគាត់ត្រឡប់មកវិញពេលណាទេ ?
- [នៅពេលដៃគូនៅចំពោះមុខអ្នក] តើខ្ញុំអាចពិភាក្សាជាមួយអ្នកបានទេ?
- [នៅពេលមានភាពជាឯកជន] ខ្ញុំជាអ្នកផ្តល់ប្រឹក្សានៅ [ឈ្មោះទីកន្លែងធ្វើការ] ។ ខ្ញុំមានព័ត៌មានសំខាន់មួយចំនួនចង់ប្រាប់អ្នក។ យើងបានដឹងថាអ្នកធ្លាប់បានប្រឈមនឹងការឆ្លងមេរោគអេដស៍។ តើអ្នកយល់យ៉ាងណាដែរ?
- ផ្តល់ព័ត៌មានដែលចាំបាច់ទាក់ទងនឹងការឆ្លងមេរោគអេដស៍ ការធ្វើតេស្ត និងការព្យាបាល៖
  - ✓ បើអ្នកមិនមានមេរោគអេដស៍ យើងអាចជួយអ្នកឱ្យនៅតែអវិជ្ជមាន
  - ✓ បើអ្នកមានផ្ទុកមេរោគអេដស៍ អ្នកអាចទទួលបានការព្យាបាលដើម្បីជួយអ្នកឱ្យរស់នៅបានយូរ និងមានសុខភាពល្អ។ ការព្យាបាលក៏អាចកាត់បន្ថយការចម្លងមេរោគអេដស៍របស់អ្នកទៅអ្នកដែលខ្លួនស្រឡាញ់បានដែរ
  - ✓ តេស្តរកមេរោគអេដស៍គឺរហ័ស ឥតគិតថ្លៃ និងមិនឈឺចាប់
- ***ប្រើសន្លឹក៣៧-៣៨ជាជំនួយប្រសិនដៃគូយល់ព្រមធ្វើតេស្ត***

# ឧបសម្ព័ន្ធទី៤៖ ការធ្វើតេស្តរកមេរោគអេដស៍
# យើងរួមគ្នា ក្នុងការការពារសុខភាពរបស់អ្នក...

## ការធ្វើតេស្ត ជាវិធីតែមួយគត់ ដើម្បីដឹងថាតើអ្នកមាន ឬគ្មានផ្ទុកមេរោគអេដស៍!



## យើងមានជម្រើសដែលត្រូវនឹងតម្រូវការរបស់អ្នក

ធ្វើតេស្ត
នៅសេវាVCCT



ធ្វើតេស្ត
ដោយខ្លួនឯង



ធ្វើតេស្តតាមអ្នក
អប់រំសហគមន៍

ប្រសិនបើមិនធ្វើតេស្តទេ!
អ្វីដែលអ្នកអាចធ្វើបាន គឺត្រឹមតែព្រួយបារម្ភ
ហើយអ្នកមិនអាចការពារខ្លួនអ្នកបានទៀត។

ធ្វើតេស្តដោយខ្លួនឯង គឺជាដំណើរការមួយដែលបុគ្គលម្នាក់
ធ្វើតេស្តរកមេរោគអេដស៍ និងបកស្រាយលទ្ធផលតេស្ត
ដោយខ្លួនឯង ឬជាមួយនរណាម្នាក់ដែលអ្នកទុកចិត្ត

**សូមថ្លែងអំណរគុណចំពោះក្រុមការងារបច្ចេកទេស និងម្ចាស់ជំនួយក្នុងកិច្ចសហការ បង្កើត "សៀវភៅ បិទ បើក" នេះដែលជាឧបករណ៍ជំនួយ សម្រាប់ការផ្តល់ប្រឹក្សា ក្នុងការតាមរកដៃគូ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើតេស្តរកមេរោគអេដស៍**

PEPFAR
USAID FROM THE AMERICAN PEOPLE
EpiC Meeting Targets and Maintaining Epidemic Control
US-CDC
CRS CATHOLIC RELIEF SERVICES